ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ៣៩ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីទៀងរាល់សប្តាហ៍

ក

មាតិកា

I . ខុទ្ទកាល័យព្រះមហាក្សត្រ

១ - ព្រះរាជក្រម

១៧-១០-១៩៩៥ -ព្រះរាជក្រម លេខ ជស/រកម/១០៩៥/០១ ច្បាប់ស្ដីពីការ ទូទាត់ថវិការដ្ឋ សំរាប់ឆ្នាំ ១៩៩៤ ២០១៨

២ - ព្រះរាជក្រឹត្យ

១១-១០-១៩៩៥ -ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០២ ២០២៥

២២-១០-១៩៩៥ -ព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៥/៧៣ ២០២៧

២២-១០-១៩៩៥ -ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៥/៧៤ ២០២៨

២២-១០-១៩៩៥ -ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៥/៧៥ ២០២៩

២៣-១០-១៩៩៥ -ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៥/៧៦ ២០៣០

II . ទីស្ដីការគណៈរដ្ឋមន្ត្រី

សារាចរ

២៤-១០-១៩៩៥ - សារាចរលេខ ០៨ សរ ស្ដីពីទំនាក់ទំនងលើគ្រប់វិស័យ រវាងស្ថាប័ននានា នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួង ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ២០៣១

III - ការិយាល័យក្រសួង

១ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

២៦-១០-១៩៩៥ – ប្រកាសលេខ ៣៤៦ ប្រក.សហវ.ពន ណែនាំអនុវត្តពន្ធ តែមប្រើសារពើពន្ធ ២០៣៣

២- ទីស្ដីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

២៤-១០-១៩៩៥ – ប្រកាសលេខ ២៦៨/៩៥ ពម.ប្រក. អនុញ្ញាតអោយបោះពុម្ពផ្សាយកាសែត«អ្នកប្រយុទ្ធ» ដែលមានលោកសិរុវុឌ្ឍី ជាម្ចាស់ហាងការផ្សាយ ២០៣៧

២៥-១០-១៩៩៥ – ប្រកាសលេខ ២៧០/៩៥ ពម.ប្រក អនុញ្ញាតអោយកាសែត «សុជីវធម៌» បោះពុម្ពផ្សាយដោយមានលោក ជឹម យ៉ាវឌ្ឍ ជាចាងហ្វាងការផ្សាយ ២០៣៨

២៥-១០-១៩៩៥ – ប្រកាសលេខ ២៧១/៩៥ ពម.ប្រក អនុញ្ញាតអោយកាសែត «អរុណ» បោះផ្សាយ ដោយមានលោក សុខ សុផាត ជាចាងហ្វាងការផ្សាយ ២០៣៩

២៦-១០-១៩៩៥ – ប្រកាសលេខ ២៧៣/៩៥ ពម.ប្រក ស្ដីពីការលុបឈ្មោះមន្ត្រីរាជការនៅមន្ទីរពត៌មានខេត្តកំពង់ស្ពឺ ២០៤០

៣ - ទីស្តីការក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

២៦-១០-១៩៩៥ – សេចក្តីសំរេចលេខ ២៣០/៩៥ កធស ស្តីពីការអនុញ្ញាត ច្បាប់អោយបង្កើតក្រុមជំនុំគ្រិស្តបរិស័ទខ្មែរ នៃនិកាយសេវេន ដេយអាត់វេនទីស្ទ ខេត្តស្វាយរៀង ២០៤១
២៧-១០-១៩៩៥ – ប្រកាសលេខ ២៣១/៩៥ កធស ស្តីពីការទទួលមន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងធម្មការ និងសាសនា ២០៤៣
២៧-១០-១៩៩៥ – ប្រកាសលេខ ២៣២/៩៥ កធស.ប្រក ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ ២០៤៤
២៨-១០-១៩៩៥ – សេចក្តីសំរេចលេខ ២៣៣/៩៥ កធស ស្តីពីការអនុញ្ញាតច្បាប់អោយធ្វើសកម្មភាពប្រតិបត្តិគ្រិស្តសាសនា នៃក្រុមជំនុំគ្រិស្តបរិស័ទ ដំណឹងល្អខ្មែរ ខេត្តបាត់ដំបង ២០៤៥
២៨-១០-១៩៩៥ – សេចក្តីសំរេចលេខ ២៣៤/៩៥ កធស ស្តីពីការអនុញ្ញាតច្បាប់អោយបើកដំណើរការ ព្រះវិហារជឿន ខ្ទមីលីក នៃសមាគមមីលីកខេត្តបាត់ដំបង ២០៤៦
២៨-១០-១៩៩៥ – សេចក្តីសំរេចលេខ ២៣៥/៩៥ កធស ស្តីពីការអនុញ្ញាតច្បាប់អោយធ្វើសកម្មភាពប្រតិបត្តិគ្រិស្តសាសនា នៃក្រុមជំនុំព្រះគ្រិស្ត បេសកកម្មផ្លូវចម្រូត ខេត្តបាត់ដំបង ២០៤៨

៤ - រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

២៤-១០-១៩៩៥ – សេចក្តីសំរេចលេខ ១០៨៧ សសរ.មស.ក្រខ ស្តីពីការបែងចែកនិស្សិត ចំនួន ០១ នាក់ ដែលទើបញ្ចប់ការសិក្សាពីក្រៅប្រទេស ២០៤៩

១៩៩៥

៥ - ទីស្តីការរដ្ឋមន្ត្រីក្រសួងផែនការ

ប្រកាស

២៥-១០-១៩៩៥ – ប្រកាសលេខ ០៧ ផក ស្តីពីការចាត់តាំងគណកម្មការប្រលងជ្រើសរើសសិស្សជំនាន់ទី VIII ចូលរៀនសាលាមធ្យមសិក្សាផែនការ ២០៥១

២៥-១០-១៩៩៥ – ប្រកាសលេខ ០៨ ផក ស្តីពីការចាត់តាំងគណៈកម្មការរៀបចំ និង ប្រធានវិញ្ញាសាប្រឡងជ្រើសរើសសិស្សជំនាន់ទី VIII ចូលរៀនសាលាមធ្យមសិក្សាផែនការ ២០៥៣

២៥-១០-១៩៩៥ – ប្រកាសលេខ ០៩ ផក ស្តីពីការចាត់តាំងគណៈមេប្រយោគសំរាប់ដំណើរការប្រលងជ្រើសរើសសិស្សជំនាន់ទី VIII ចូលរៀនសាលាមធ្យមសិក្សាផែនការ ២០៥៤

២៥-១០-១៩៩៥ – ប្រកាសលេខ ១០ ផក ស្តីពីការចាត់តាំងអនុគណៈកម្មការត្រួតពិនិត្យសំរាប់ដំណើរការប្រលងជ្រើសសិស្សជំនាន់ទី VIII ចូលរៀន សាលាមធ្យមសិក្សាផែនការ ២០៥៦

២៥-១០-១៩៩៥ – ប្រកាសលេខ ១១ ផក ការចាត់តាំងអនុគណៈកម្មការកណ្តាល និងក្រុមជំនួយការ សំរាប់ដំណើរការប្រលងជ្រើសរើសសិស្សជំនាន់ទី VIII ចូលរៀន សាលាមធ្យមសិក្សាផែនការ ២០៥៧

២៥-១០-១៩៩៥ – ប្រកាសលេខ ១២ ផក ស្តីពីការចាត់តាំងគណៈកម្មការកំណែវិញ្ញាសា ប្រលងជ្រើសរើសសិស្សជំនាន់ទី VIII ចូលរៀនសាលាមធ្យមសិក្សាផែនការ ២០៥៩

២៥-១០-១៩៩៥ – ប្រកាសលេខ ១៣ ផក ស្តីពីការចាត់តាំងអនុគណៈកម្មការដំណើរការកែ ការប្រលងជ្រើសរើសសិស្សចូលរៀនសាលាមធ្យមសិក្សាផែនការ ២០៦១

២៥-១០-១៩៩៥ – ប្រកាសលេខ ១៤ ផក ស្តីពីការចាត់តាំងអនុគណៈកម្មការអនុរក្ស ដំណើរការប្រលងជ្រើសរើសសិស្សជំនាន់ទី VIII ចូលរៀនសាលាមធ្យមសិក្សាផែនការ ២០៦៤

៦ - ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

២៧-១០-១៩៩៥ - ប្រកាសលេខ ៧៨៩ ផក.ប្រក អនុញ្ញាតអោយលោក
ហេង ម៉ុយ ជនជាតិខ្មែរ បន្តដំណើរការផលិតកម្ម
និង ពង្រីកបន្ថែមនូវមុខ ផលិតផលស្រាកែច្នៃ ២០៦៧

២៧-១០-១៩៩៥ - ប្រកាសលេខ ៧៩០ ផក.ប្រក អនុញ្ញាតអោយលោក
ឈុន គេង ជនជាតិខ្មែរ បន្តដំណើរការផលិតកម្ម
ពង្រីកបន្ថែមនូវមុខផលិតផលស្រាកែច្នៃ ២០៦៨

២៧-១០-១៩៩៥ - ប្រកាសលេខ ៧៩១ ផក.ប្រក អនុញ្ញាតអោយលោក
ជឹម គីអៀង ជនជាតិខ្មែរ បន្តដំណើរការផលិតកម្ម
ពង្រីកបន្ថែមនូវមុខផលិតផលស្រាកែច្នៃ ២០៦៨

២៧-១០-១៩៩៥ - ប្រកាសលេខ ៧៩៣ ផក.ប្រក អនុញ្ញាតអោយលោក
ពេជ្រ សុវណ្ណ ជនជាតិខ្មែរ បន្តដំណើរការផលិតកម្ម
ពង្រីកបន្ថែមនូវមុខផលិតផលថ្នាំលាប ២០៦៩

២៧-១០-១៩៩៥ - ប្រកាសលេខ ៧៩៤ ផក.ប្រក អនុញ្ញាតអោយលោក
ឡេង សុខឃាន ជនជាតិខ្មែរ បន្តដំណើរការផលិតកម្ម
ទឹកកកដើម ២០៧០

២៨-១៩-១៩៩៥ - ប្រកាសលេខ ៧៩៥ ផក.ប្រក អនុញ្ញាតអោយលោក
ម៉ែន ចាន់ណា ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីន
ផលិតថាមពលអគ្គិសនីដោយ ប្រើម៉ាស៊ីនចំនួន ០២គ្រឿង ២០៧១

២៨-១៩-១៩៩៥ - ប្រកាសលេខ ៧៩៦ ផក.ប្រក អនុញ្ញាតអោយលោក
ឈឹម ហុង ជនជាតិខ្មែរ បន្តដំណើរការផលិតកម្ម និង
ពង្រីកបន្ថែមនូវមុខផលិតផលស្រាកែច្នៃ ២០៧១

ច

៧_ទីស្ដីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប្រកាស

២៦-១៩-១៩៩៥ – ប្រកាសលេខ ១៧៣ ប្រក.វវស.បុ ស្ដីពីការតែងតាំង
មន្ត្រីរាជការមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត ព្រះវិហារ ២០៧២

I - ខុទ្ទកាល័យព្រះមហាក្សត្រ

១ - ព្រះរាជក្រម

ព្រះរាជក្រមលេខ នស.រកម.១០៩៥.០១

ច្បាប់ស្តីពីការទូទាត់ថវិការដ្ឋសំរាប់ឆ្នាំ ១៩៩៤

យើងព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

* * * * *

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីទេស រដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាសអោយប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការទូទាត់ ថវិការដ្ឋសំរាប់ ឆ្នាំ ១៩៩៤ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់ស្តីពីការទូទាត់ថវិការដ្ឋសំរាប់ឆ្នាំ ១៩៩៤

ភាគទី ១
បទបញ្ញត្តិ នៃច្បាប់ស្តីពីការទូទាត់ថវិការដ្ឋ

ជំពូកទី ១
បទបញ្ញត្តិទូទៅ

មាត្រា ១ : ត្រូវបានយល់ព្រមតាមការអនុវត្តន៍ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយដោយព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ហើយត្រូវបានកែប្រែដោយច្បាប់ ស្តីពីការកែតម្រូវ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើដោយព្រះរាជក្រម លេខ ០៨ ន.ស៩៤ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ។ ការអនុវត្តន៍នេះ លេចចេញជាលទ្ធផល ÷

- សរុបចំណាយចំនួន .... ១.០២០.១៣២ លានរៀល
- សរុបចំណូលចំនួន .... ១.០០២.០១៧ លានរៀល

ដូចមានចែងក្នុងតារាងខាងក្រោមនេះ ÷ ឯកតា : លានរៀល

១–សរុបចំណូលចំណាយ នៃកិច្ចប្រតិបត្តិការត្រូវបានបញ្ចាក់ដោយមានលក្ខណៈថវិកាបង្គាល ពីព្រោះកិច្ចប្រតិបត្តិការដែលអនុវត្តបានដោយហិរញ្ញប្បទានក្រៅប្រទេស មិនឆ្លងកាត់រតនាគារជាតិ ហើយមិនបានចុះកិច្ចបញ្ជីការក្នុងគណនេយ្យរតនាគារទេ ។ កិច្ចប្រតិបត្តិការ នេះគ្រាន់តែជាកម្មវត្ថុ នៃការប៉ាន់ប្រមាណតួលេខមួយ ក្រោយពីមានការពិគ្រោះព្រមព្រៀងគ្នា ជាមួយអ្នកផ្តល់មូលនិធិ ។ ក្រោយពីមានការពិគ្រោះព្រមព្រៀងគ្នាជាមួយអ្នកផ្តល់មូលនិធិ ។ ចំណែកឯចំណាយមួយភាគរបស់ក្រសួងការពារជាតិក៏មិនបានចុះកិច្ចបញ្ជីការនៅក្នុងគណនេយ្យ រតនាគារជាតិដែរ ហើយការចំណាយនេះត្រូវបានផ្តល់ហិរញ្ញប្បទានដោយការខ្ចី ចុះពីផ្នែកឯកជន ខាងក្រៅនិង ក្នុងប្រទេសព្រមទាំងដោយប្រភពធនធានជាតិដែលពាក់ព័ន្ធ ។

ជំពូកទី ២
បទបញ្ញត្តិស្តីពីកិច្ចប្រតិបត្តិការថវិកា

មាត្រា ២ : ការប្រមូលចំណូលជាគុណប្រយោជន៍ នៃថវិកាទូទៅរបស់រដ្ឋពីពន្ធដារ វិភាគទាន អាករផលិតផល និង ផលទុន ព្រមទាំងការធ្វើអោយសំរេចនូវ អំណោយមូលនិធិធិបដិភាគ និង ធនធានបានមកពី ការខ្ចីបុលដែលបានអនុញ្ញាតអោយគ្រោងទុកនៅក្នុងច្បាប់ ស្តីពីការតម្រូវ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤ មានទឹកប្រាក់សរុប ៦៣៧.៥០០ លានរៀល

ការអនុវត្តន៍បានមានចំនួនទឹកប្រាក់	៦៧៧.១៦២ លានរៀល
ដូច្នេះមានចំណូលលើសចំនួន	៣៩.៦៦២ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តដូចតទៅ ÷

– ចំណូលផ្ទៃក្នុងជាប្រចាំ	: គំរោងកែតម្រូវ	៤៩៦.៧០០ លានរៀល
	: សំរេចបាន	៥៦៥.២៧០ លានរៀល
	: មានចំនួនលើស	៦៨.៥៧០ លានរៀល
– ចំណូលផ្ទៃក្នុងជាមូលធន	: គំរោងកែតម្រូវ	២៣.៨០០ លានរៀល
	: សំរេចបាន	១.២៣៧ លានរៀល
	: មានចំនួនខ្វះ	២២.៥៦៣ លានរៀល
– ចំណូលខាងក្រៅជាមូលធន:	គំរោងកែតម្រូវ	១១៧.០០០ លានរៀល
	: សំរេចបាន	១១០.៦៥៥ លានរៀល
	: មានចំនួនខ្វះ	៦.៣៤៥ លានរៀល

មាត្រា ៣ : ចំណាយថវិកាទូទៅរបស់រដ្ឋដែលត្រូវទទួលការអនុវត្តន៍តាមការគ្រោងទុកនៅក្នុងច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤

មានចំនួនទឹកប្រាក់សរុប	៦៣៧.៥០០ លារៀល
ការអនុវត្តន៍បានមានចំនួនទឹកប្រាក់	៦៨០.៥៣៧ លានរៀល
ដូច្នេះមានចំនួនលើស	២១.៥៤៧ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តដូចតទៅ ÷

–ចំណាយជាប្រចាំ	: គំរោងកែតម្រូវ	៥៨៥.៦០០	លានរៀល
	: សំរេចបាន	៥៨៩.៥៨៨	លានរៀល
	: មានចំនួនលើស	៤.១៣៨	លានរៀល
– ចំណាយជាមូលធន	: គំរោងកែតម្រូវ	៥១.៩០០	លានរៀល
	: សំរេចបាន	៦៩.៣០៩	លានរៀល
	:មានចំនួនលើស	១៧.៤០៩	លានរៀល

មាត្រា ៤ : ការអនុវត្តន៍កិច្ចប្រតិបត្តិការចំណូលចំណាយតាមច្បាប់ ស្តីពីការកែតម្រូវ នៃច្បា ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៤ ដែលសំរេចបានដោយ រតនាគារជាតិ បានបញ្ជាក់នៅក្នុងមាត្រា ២ និង ៣ ខាងលើ បានបង្ហាញជាលទ្ធផលនូវចំណូ លើសចំណាយដូចតទៅ :

– ចំណូលថវិកាដែលសំរេចបានដោយរតនាគារ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៤....................... ៦៧៧.១៦២ លានរៀល

– ចំណាយថវិកាដែលសំរេចបានដោយរតនាគារ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៤....................... ៦៥៩.០៤៧ លានរៀ

– ចំនួនលើសនៃគណនេយ្យនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤ : ១៨.១១៥ លានរៀ

ដោយអនុលោមទៅតាមបទបញ្ញត្តិក្នុងមាត្រា ៥៧ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរ វត្ថុដែល ប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ឆ្នាំ ១៩៩៣ ចំនួន លើសនៃគណនេយ្យនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ មានចំ ទឹកប្រាក់ ១៨.១១៥ លានរៀល ត្រូវបានកត់ត្រានៅ « គណនីលទ្ធផលរតនាគារ ដែលបានបើកនៅក្នុងគណនេយ្យរតនាគារជាតិ ។

ជំពូកទី ៣

បទបញ្ញត្តិស្តីពីកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ ដែលបានអនុវត្តក្រៅរតនាគារជាតិ

មាត្រា ៥ : ត្រូវបានយល់ព្រមតាមការអនុវត្តន៍កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ ក្រៅរតនាគារជាតិនូវចំណូល ដែលសំរេចបាននិងចំណាយលើសពីការអនុញ្ញាតនៃថវិកាទូទៅមានទឹកប្រាក់ដូចតទៅ ÷

សរុបចំណូល.............................. ៨៦.១៨១ លានរៀល
- ចំណូលផ្ទៃក្នុងជាប្រចាំ.......... .... ២៣.៩០២ លានរៀល
- ចំណូលផ្ទៃក្នុងជាមូលធន........................ ១៩.១១២ លានរៀល
- ចំណូលខាងក្រៅជាមូលធន..................... ៤៣.១៦៧ លានរៀល

សរុបចំណាយ................................... ៨៦.១៨១ លានរៀល
- ចំណាយជាប្រចាំ................................ ៧២.៦៦៤ លានរៀល
- ចំណាយជាមូលធន.:.......................... ១៣.៥១៧ លានរៀល

ជំពូកទី ៤

បទបញ្ញត្តិស្តីពីវិនិយោគសាធារណៈដោយ ហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ក្រៅរតនាគារ

មាត្រា ៦ : វិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ក្រៅរតនាគារដែល បានគ្រោងចំណូល ចំណាយនៅក្នុងច្បាប់ស្តីពីការកែតម្រូវច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤

មានចំនួនទឹកប្រាក់ ២៥២.១០០ លានរៀល
ការប៉ាន់ប្រមាណអនុវត្តបានមានចំនួនទឹកប្រាក់ ២៥៦.៧៨៩ លានរៀល
គឺមានចំនួនលើស ៤.៦៨៩ លានរៀល

ជំពូកទី ៥
អវសានបញ្ញត្តិ

មាត្រា ៧ : ចំណូលលំអិតតាមមាតិកាថវិកាត្រូវបានបញ្ជាក់នៅតារាង «ក » ក្នុងភាគទី ២ នៃច្បាប់នេះ ។

ចំណាយអិត តាមក្រសួង និងស្ថាប័នសាធារណៈប្រហាក់ប្រហែល និងតាមប្រភេទតាមជំពូក ត្រូវបានបញ្ជាក់នៅតារាង «ខ » ក្នុងភាគទី ២ នៃច្បាប់នេះ ។

តារាង «ខ១ » គឺជាបញ្ជីនៃគំរោងវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្នុងប្រទេស ដែលសំរេចបានក្នុងរយៈពេលនៃការគ្រប់គ្រងឆ្នាំ ១៩៩៤ និងត្រូវបានបែងចែកតាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែល ។

ការប៉ាន់ប្រមាណសំរេចបាន ស្តីពីវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ចំពោះចំណូលត្រូវបានលំអិតតាមមាតិកាថវិកា និង ចំពោះចំណាយ តាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែលត្រូវបានបញ្ជាក់ជាបន្តបន្ទាប់ នៅតាមតារាង «ក » និង «ខ» ក្នុងភាគទី២ នៃច្បាប់នេះ ។

តារាង «ខ២» គឺជាបញ្ជីនៃគំរោងវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលសំរេចបានក្នុងរយៈពេលនៃការគ្រប់គ្រងឆ្នាំ ១៩៩៤ និងត្រូវបានបែងចែកតាមក្រសួង និង ស្ថាប័នសាធារណៈ ប្រហាក់ប្រហែលដោយអ្នកផ្តល់ប៉រទេស ។

កិច្ចប្រតិបត្តិការនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ ឆ្នាំ ១៩៩៤	ច្បាប់ហិរញ្ញវត្ថុដើម	ច្បាប់ហិញ្ញវត្ថុកែតម្រូវ	ច្បាប់ហិរញ្ញវត្ថុតាមការអនុវត្តបាន
សរុបចំណូល ១	៨៨៩.៦០០	៨៨៩.៦០០	១.០២០.១៣២
សរុបចំណាយ	៨៨៩.៦០០	៨៨៩.៦០០	១.០០២.០១៧
ចំណូលលើសចំណាយ			១៨.១១៥
កិច្ចប្រតិបត្តិការនៃច្បាប់ហិរញ្ញវត្ថុតាម			

ការអនុវត្តន៍បានដោយរតនាគារជាតិ	៦២៣.៣០០	៦៣៧.៥០០	៦៧៧.១៦២
ចំណូលថវិកា			
– ចំណូលផ្ទៃក្នុងជាប្រចាំ	៤៦០.០០០	៤៩៦.៧០០	៥៦៥.២៧០
– ចំណូលផ្ទៃក្នុងជាមូលធន	០	២៣.៨០០	១.២៣៧
– ចំណូលខាងក្រៅជាមូលធន	១៦៣.៣០០	១១៧.០០០	១១០.៦៥៥
– ចំណាយថវិកា	៦២៣.៣០០	៦៣៧.៥០០	៦៥៩.០៤៧
– ចំណាយជាប្រចាំ	៥៧៧.៦០០	៥៨៥.៦០០	៥៨៩.៥៨៨
– ចំណាយជាមូលធន	៤៥.៧០០	៥១.៩០០	៦៩.៤៥៩
កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ របស់រដ្ឋដែលអនុវត្តក្រៅរតនាគារ ជាតិចំណូលថវិកា			៨៦.១៨១
– ចំណូលផ្ទៃក្នុងជាប្រចាំ			២៣.៩០២
– ចំណូលផ្ទៃក្នុងជាមូលធន			១៩.១១២
– ចំណូលខាងក្រៅជាមូលធន			៤៣.១៦៧
ចំណាយថវិកា			៨៦.១៨១
– ចំណាយជាប្រចាំ			៧២.៦៦៤
– ចំណាយជាមូលធន			១៣.៥១៧
វិនិយោគសាធារណៈដោយហិរញ្ញប្បទាន ក្រៅប្រទេសផ្ទាល់ ដែលអនុវត្តក្រៅរតនាគារ ធនធានជាមូលធន សំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេស	២៦៦.៣០០	២៥២.១០០	២៥៦.៧៨៩
ចំណាយជាមូលធនដោយធនធាន សំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេស	២៦៦.៣០០	២៥២.១០០	២៥៦.៧៨៩

មាត្រា ៨ : បទបញ្ញត្តិនៃច្បាប់ទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៥

ក្នុងព្រះបរមនាម និង តាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ព្រះហស្តលេខា ហត្ថលេខា

នរោត្តម រណឫទ្ធិ ហ៊ុន សែន

បានបង្គំទូលថ្វាយ និង ជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២

ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការ

នីតិសម្បទា និង អភិវឌ្ឍន៍ និងជា

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

* * *

២ - ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានទ្រង់យល់ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
– បានទ្រង់យល់ព្រះរាជក្រមចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងសហអគ្គមេបញ្ជាការនៃកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា
– បានទ្រង់យល់ព្រះរាជក្រឹត្យចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការដ្ឋាននៃកងកម្លាំងជាតិកម្ពុជា
– ទ្រង់បានយល់ព្រះរាជក្រឹត្យលេខ ជស–រកត–១២៩៤–១៨ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតអគ្គមេបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
– យោងតាមសំណើលេខ ៧៤ លស ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៥ របស់នាយករដ្ឋមន្ត្រី ទី ១ នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា និងសហអគ្គមេបញ្ជាការនៃកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំង ឯកឧត្តមឧត្តមសេនីយ៍ឯក **ខៀវ ឈាញ់** និង ឯកឧត្តម ឧត្តមសេនីយ៍ឯក **នា ចំរាត់** ជាសហអគ្គមេបញ្ជាការរងនៃកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា កងកម្លាំងជំនួយ កងកម្លាំងនគរបាល និង កម្លាំងសន្តិសុខកម្ពុជា ។

មាត្រា ២ : សហអគ្គមេបញ្ជាការរងនៃកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជាដែលត្រូវបានតែងតាំងខាងលើ មានមុខងារជាអ្នកជំនួយការងារអោយសហអគ្គមេបញ្ជាការក្នុងការដឹកនាំបញ្ជាគ្រប់គ្រងកងកម្លាំង ប្រដាប់អាវុធជាតិកម្ពុជារួមទាំងកងកម្លាំងនគរបាលជាតិ កម្លាំងសន្តិសុខ និងកម្លាំង ជំនួយផ្សេងៗ ។

មាត្រា ៣ : នៅក្រោមបញ្ជាផ្ទាល់របស់សហអគ្គបញ្ជាការ និង សហអគ្គមេបញ្ជាការរង នាយអគ្គសេនាធិការ ជាអ្នកជំនួសមុខក្នុងការដឹកនាំបញ្ជាគ្រប់គ្រងជា ប្រចាំចំពោះកងយោធពលខេមរភូមិន្ទ និង កងកម្លាំងជំនួយផ្សេងៗ ។ អគ្គនាយកនគរបាលជាតិជាអ្នកជំនួសមុខក្នុងការដឹកនាំបញ្ជាគ្រប់គ្រង ជាប្រចាំចំពោះកងកម្លាំងនគរបាលជាតិ និងកម្លាំងសន្តិសុខ ។

មាត្រា ៤ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា និង សហអគ្គមេបញ្ជាការ នៃ កងកម្លាំងប្រដាប់អាវុធជាតិកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត អោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩៥

ក្នុងព្រះបរមនាម និង

តាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៥/៧៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្សអគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលជាតិ កម្ពុជា ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសឱ្យប្រើ

មាត្រា ១ : តែងតាំងជាទីប្រឹក្សាសម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ នៃរាជរដ្ឋាភិបាល កម្ពុជា នូវឥស្សរជនដូចរាយនាមខាងក្រោម :

–ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ជីវ័ន មុនីរក្ស** ជាទីប្រឹក្សា ទទួលបន្ទុកយោធាមានឋានៈ ស្មើរដ្ឋមន្ត្រី

– ឯកឧត្តម **ហ្លួត ម៉ុងលី** ជាទីប្រឹក្សា ទទួលបន្ទុកកិច្ចការយោធា មានឋានៈស្មើ អនុរដ្ឋលេខាធិការ

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុក អនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ

លេខ នស/រកត/១០៩៥/៧៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

* * *

– បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាល ជាតិ កម្ពុជា ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩៥

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **មាសកេត្ត ពេជ្ររ៉ាន** ជាអនុរដ្ឋលេខាធិការនៃក្រសួងសាធារណការ និង ដឹកជញ្ជូនជំនួសឯកឧត្តម **ឌួង សាំខន** ។

មាត្រា ២ : នាកយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៥

ព្រះហស្ថលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ

លេខ នស/រកត/១០៩៥/៧៥

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស
ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម
ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជា ធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលជាតិ កម្ពុជា ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម ឧត្តមសេនីយ៍ទោ **គង់ គីម** បេសកជនពិសេសរបស់សម្តេចនាយក រដ្ឋមន្ត្រីទី ២ មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ

លេខ នស/រកត/១០៩៥/៧៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលជាតិ កម្ពុជា ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៩៥

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ឃី តាំងលីម** ជាអនុប្រធានទី ២ នៃគណៈកម្មាធិការជាតិទន្លេមេគង្គនិងជាសមាជិកគណៈកម្មការរួមនៃគណៈកម្មាធិការទន្លេមេគង្គ មានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា ២ ; នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

II - ឯកសារគណៈរដ្ឋមន្ត្រី

សារាចរ

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៥

សារាចរ លេខ/០៨/សរ

ស្តីពីទំនាក់ទំនងលើគ្រប់វិស័យ រវាងស្ថាប័ននានានៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

កន្លងមកក្នុងការធ្វើទំនាក់ទំនងជាមួយបរទេស និង រវាងក្រសួង ស្ថាប័ន ខេត្ត–ក្រុង ជាមួយស្ថានឯកអគ្គរាជទូត ស្ថានកុងស៊ុល និង ស្ថានបេសកកម្មអចិន្ត្រៃយ៍នានា នៃ ព្រះរាជា

ណាចក្រកម្ពុជានៅបរទេស ពុំបានអនុវត្តត្រឹមត្រូវតាមគោលការណ៍ ច្បាប់ទំលាប់អន្តរជាតិនៅ ឡើយជាហេតុជះឥទ្ធិពលមិនល្អដល់ប្រសិទ្ធភាពការងារ និង កិត្យានុភាពរបស់រាជរដ្ឋាភិបាល ។

ដើម្បីជៀសវាងផលវិបាកអាក្រក់ជាយថាហេតុ និង សំដៅធានាបានរបៀបរបបការងារ មួយមានប្រសិទ្ធភាព រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួង ស្ថាប័ន ខេត្ត–ក្រុង និង ស្ថានឯកអគ្គរាជទូត ស្ថានកុងស៊ុល និង ស្ថានបេសកកម្មអចិន្ត្រៃយ៍នានា នៃព្រះរាជាណាចក្រ កម្ពុជាដូចតទៅ :

១–រាល់ការចរចា ឬ ចុះកិច្ចព្រមព្រៀងផ្លូវការរវាងក្រសួង ស្ថាប័ន ខេត្ត–ក្រុងនានា ជាមួយស្ថានទូត ស្ថានបេសកកម្មបរទេស ឬ សមភាគីបរទេសដទៃទៀតនៅព្រះរាជាណាចក្រ កម្ពុជា ចាំបាច់ត្រូវមានការ ចូលរួមមតិ នយោបាយការទូត និងច្បាប់អន្តរជាតិពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

២–រាល់ការចរចា ឬ ចុះកិច្ចព្រមព្រៀងផ្លូវការរវាងក្រសួង ស្ថាប័ន ខេត្ត–ក្រុងនានា ដែលប្រព្រឹត្ត ទៅនៅបរទេស ចាំបាច់ត្រូវមានការចូលរួមមតិពីសំណាក់ ស្ថានឯកអគ្គរាជទូត កុងស៊ុល ឬ ស្ថានបេសកកម្ម អចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ។ ស្ថានទូត ស្ថានកុងស៊ុល ស្ថានបេសកកម្មទាំងនោះត្រូវរាយការណ៍អំពីលទ្ធផល ឬ បញ្ហាបន្ទាន់ មកក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

៣–ទំនាក់ទំនងខាងលិខិតស្នាម និង សំណើផ្សេង ៗ ជាផ្លូវការរាប់ទាំងការសុំទិដ្ឋាការ របស់ក្រសួង ស្ថាប័ន ខេត្ត–ក្រុង ជាមួយស្ថានទូត ស្ថានបេសកកម្មបរទេស ឬ សមភាគីបរទេស ទាំងនេះ ត្រូវឆ្លងតាមរយៈ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

៤–ដើម្បីសម្រួលទស្សនកិច្ចផ្លូវការនៅបរទេស នៃ មន្ត្រីរាជការ ឬ ដំណើរទៅធ្វើកម្មសិក្សា ព្រមទាំង ការចេញដំណើររបស់និស្សិតទៅបន្តការសិក្សា កីឡាករទៅប្រកួត ឬ ក្រុមសិល្បករទៅ សំដែងនៅបរទេស។ល។ ចាំបាច់ត្រូវជូនដំណឹងទៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរ ជាតិអំពី :

៤–១–សមាសភាព និង លិខិតឆ្លងដែន

៤–២–គោលបំណង និង កម្មវិធី

៤–៣–កាលបរិច្ឆេទចេញដំណើរ និង ទៅដល់រយៈពេលស្នាក់នៅ ។ ល ។

៤–៤–ជើងយន្តហោះផ្លូវហោះហើរ ឬ ឆ្លងកាត់

ពេលចប់បេសកកម្ម គណៈប្រតិភូ ឬ បេសកកម្មជនទាំងនេះត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផល សកម្មភាពជូនរាជរដ្ឋាភិបាលដោយមានចំលងមួយច្បាប់ជូនទៅក្រសួងការបរទេស និង សហប្រតិបត្តិការ អន្តរជាតិដើម្បីមុខការ ។

៥_រាល់សំណើ ឬ របាយការណ៍ ឬ លិខិតស្នាមរបស់ស្ថានឯកអគ្គរាជទូត ស្ថានកុងស៊ុល និង ស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជានៅបរទេសផ្ញើចំពោះក្រសួង ស្ថាប័ន ខេត្ត_ក្រុងនានា នៃ ព្រះរាជាណាចក្រកម្ពុជា ចំបាច់ត្រូវឆ្លងកាត់តាមរយៈក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

ក្នុងស្មារតីបំរើផលប្រយោជន៍ប្រទេសជាតិ រាជរដ្ឋាភិបាលសូមអោយគ្រប់ក្រសួង ស្ថាប័ន ខេត្ត_ ក្រុង គ្រប់ស្ថានកុងស៊ុល និង ស្ថានបេសកកម្មអចិន្ត្រៃយ៍ទាំងអស់ នៃ ព្រះរាជាណាចក្រកម្ពុជានៅបរទេស អនុវត្តសារាចរនេះបានពេញលេញ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	ហ៊ុន សែន

* * *

III- ការិយាល័យ/បណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ/៣៤៦/ប្រក.សហវ.៣ដ

ណែនាំអនុវត្តពន្ធតែមប្រ៊ីសារពើពន្ធ

ទេសរដ្ឋមន្ត្រី

* * *

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

– បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតតែមប្រើសារពើពន្ធ ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ២៣ ក្រ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៩១
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៩១ ស្តីពីការប្រមូលពន្ធ តែមប្រើសារពើពន្ធ
- បានឃើញប្រកាសលេខ ០៣៧ ប្រក.កហវ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩១ ស្តីពីការណែនាំអនុវត្ត អនុក្រឹត្យស្តីពីការប្រមូលពន្ធតែមប្រើសារពើពន្ធ
- បានឃើញប្រកាសលេខ ០១៤ ប្រក.សហវ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ ស្តីពីការកែប្រែ រូបភាពតែមប្រើសារពើពន្ធ
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការកែលំអ និង បំពេញបន្ថែមអនុក្រឹត្យស្តីពីការប្រមូលពន្ធតែមប្រើសារពើពន្ធ
- យោងតាមការងារចំបាច់ក្នុងការងារប្រមូលពន្ធតែមប្រើសារពើពន្ធ

សំរេច

ប្រការ ១ : សន្លឹកតែមប្រើសារពើពន្ធត្រូវបានបែងចែកជា ៥ ប្រភេទគឺ : សន្លឹកតែមប្រើសារពើពន្ធមានតំលៃ១០០ រៀល ២០០ រៀល ៥០០ រៀល ១.០០០ រៀល និង ២.០០០ រៀល ។

ប្រការ ២ : ទំហំសន្លឹកតែមប្រើសារពើពន្ធគ្រប់ប្រភេទមានរាងចតុកោណកែង និងមានខ្នាតដូចតទៅ :

–ទទឹងមានប្រវែង ១,៨០ សម

–បណ្ដោយមានប្រវែង ៣,៤០ សម

ប្រការ ៣ : អំពីរូបភាពតែមប្រើ :

១–សន្លឹកតែមប្រើសារពើពន្ធមានតំលៃ ១០០ រៀល :

–មានហាមព័ទ្ធជុំវិញពណ៌លឿងទុំ ដែលរំលេចដោយក្បាច់បែបបុរាណខ្មែរ

–ផ្ទៃក្នុងភាគខាងឆ្វេងមានរូបហង្សមួយ ដែលស្ថិតក្នុងរង្វង់មូលបីជាន់ព័ទ្ធជុំវិញ នៅក្នុងរង្វង់មូល ផ្នែកខាងលើមានសរសេរអក្សរ « ព្រះរាជាណាចក្រកម្ពុជា » ផ្នែកខាងក្រោមមានសរសេរអក្សរ ឡាតាំង « **Royaume du Cambodge** » ដែលមានពណ៌លឿងទុំដែរ ។

–ផ្ទៃក្នុងភាគខាងស្ដាំមានសរសេរអក្សរ « តែមប្រើសារពើពន្ធ ១០០ រៀល **Timbre Fiscal** » ពណ៌ខៀវ ។

២–សន្លឹកតែមប្រើសារពើពន្ធមានតំលៃ ២០០ រៀល :

–មានហាមព័ទ្ធជុំវិញផ្កាឈូក ដែលរំលេចដោយក្បាច់បែបបុរាណខ្មែរ

–ផ្ទៃក្នុងភាគខាងឆ្វេងមានរូបហង្សមួយ ដែលស្ថិតក្នុងរង្វង់មូលបីជាន់ព័ទ្ធជុំវិញ នៅក្នុងរង្វង់ មូលផ្នែកលើមានសរសេរអក្សរ « ព្រះរាជាណាចក្រកម្ពុជា » ផ្នែកខាងក្រោមមានសរសេរអក្សរឡាតាំង" **Royaume du Cambodge**" ដែលមានពណ៌ផ្កាឈូកដែរ ។

–ផ្ទៃក្នុងភាគខាងស្ដាំមានសរសេរអក្សរ « តែមប្រើសារពើពន្ធ ២០០ រៀល **Timbre Fiscal** ពណ៌ខៀវទឹកសមុទ្រ ។

៣–សន្លឹកតែមប្រើសារពើពន្ធមានតំលៃ ៥០០ រៀល :

–មានហាមព័ទ្ធជុំវិញពណ៌ខៀវ ដែលរំលេចដោយក្បាច់បែបបុរាណខ្មែរ

–ផ្ទៃក្នុងភាគខាងឆ្វេងមានរូបហង្សមួយ ដែលស្ថិតក្នុងរង្វង់មូលបីជាន់ព័ទ្ធជុំវិញ នៅក្នុងរង្វង់មូល ផ្នែកខាងលើមានសរសេរអក្សរ « ព្រះរាជាណាចក្រកម្ពុជា » ផ្នែកខាងក្រោយមានសរសេរអក្សរឡាតាំង " **Royaume du Cambodge** " ដែលមានពណ៌ខៀវដែរ ។

–ផ្នែកក្នុងភាគខាងស្តាំមានសរសេរអក្សរ « តែមប្រើសារពើពន្ធ ៥០០ រៀល Timbre Fiscal ពណ៌ក្រហម ។

៤_សន្លឹកតែមប្រើសារពើពន្ធតំលៃ ១.០០០ រៀល :

–មានហាមព័ទ្ធជុំវិញពណ៌បៃតង ដែលរំលេចដោយក្បាច់បែបបុរាណខ្មែរ

–ផ្នែកក្នុងភាគខាងឆ្វេងមានរូបហង្សមួយ ដែលស្ថិតក្នុងរង្វង់មូលបីជាន់ព័ទ្ធជុំវិញ នៅក្នុងរង្វង់មូល ផ្នែកខាងលើមានសរសេរអក្សរ « ព្រះរាជាណាចក្រកម្ពុជា » ផ្នែកខាងក្រោមមានសរសេរអក្សរឡាតាំង " Royaume du Cambodge " ដែលមានពណ៌បៃតងដែរ ។

–ផ្នែកក្នុងភាគខាងស្តាំមានសរសេរអក្សរ « តែមប្រើសារពើពន្ធ ១.០០០ រៀល Timbre Fiscal ពណ៌ក្រហម ។

៥_សន្លឹកតែមប្រើសារពើពន្ធមានតំលៃ ២.០០០ រៀល :

–មានហាមព័ទ្ធជុំវិញពណ៌ក្រហមចាស់ ដែលរំលេចដោយក្បាច់បែបបុរាណខ្មែរ

–ផ្នែកក្នុងភាគខាងឆ្វេងមានរូបហង្សមួយ ដែលស្ថិតក្នុងរង្វង់មូលបីជាន់ព័ទ្ធជុំវិញ នៅក្នុងរង្វង់មូល ផ្នែកខាងលើមានសរសេរអក្សរ « ព្រះរាជាណាចក្រកម្ពុជា » ផ្នែកខាងក្រោមមានសរសេរអក្សរឡាតាំង " Royaume du Cambodge " ដែលមានពណ៌ក្រហមចាស់ដែរ ។

–ផ្នែកក្នុងភាគខាងស្តាំមានសរសេរអក្សរ « តែមប្រើសារពើពន្ធ ២.០០០ រៀល Timbre Fiscal ពណ៌ខៀវទឹកប៊ិច ។

ប្រការ ៤ : ប្រាក់ពន្ធតែមប្រើ ត្រូវបង់តាមតារាងពន្ធតែមប្រើ ដូចមានចែងក្នុងអនុក្រឹត្យលេខ ៧៦ អនក្រ. បក ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការកែលំអ និងបំពេញបន្ថែមអនុក្រឹត្យស្តីពីការ ប្រមូលពន្ធតែមប្រើសារពើពន្ធ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ឆាយ ថន

* * *

២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងព័ត៌មាន

ប្រកាស

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ/២៦៨/៩៥/ពម.ប្រក

អនុញ្ញាតអោយកាសែត «អ្នកប្រយុទ្ធ»

ដំណើរការបោះពុម្ពផ្សាយ

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជាជំពូកអវសានបញ្ញត្តិមាត្រាទី ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម ០៨៩៥/០៧ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ១៩៩៥ ប្រកាសអោយប្រើច្បាប់ស្តីពីរបបសារព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសំណើសុំរបស់លោក **សំ ទុន្សី** ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយកាសែត «អ្នកប្រយុទ្ធ» ដែលមានលោក **សំ ទុន្សី** ជាម្ចាស់ក្រុមហ៊ុនការផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និង សកម្មភាពផ្សព្វផ្សាយត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន ព្រមទាំងស្នើប្រគល់កាសែតចំនួន ០៦ ច្បាប់រៀងរាល់លេខបោះពុម្ពផ្សាយ ដើម្បីតំកល់ទុកជាឯកសារនៅក្រសួងព័ត៌មាន ។

ប្រការ ៤ : លោក **សំ ឧត្តរ៉ា** ចាងហ្វាងការផ្សាយ និង នាយកដ្ឋានមណ្ឌលពត៌មាននៃក្រសួងពត៌មានត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

ប្រកាស

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៥

លេខ/២៦៩/៩៥/ពម.ប្រក

ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការមន្ត្រីរាជការ

* * *

- បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញចំណារយល់ព្រមទទួល ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់ឯកឧត្តមអនុរដ្ឋលេខាធិការ ក្រសួងអប់រំយុវជន និង កីឡា
- ពិនិត្យលើលិខិតសុំផ្លាស់កន្លែងធ្វើការរបស់សាមីខ្លួន

សំរេច

ប្រការ ១ : យល់ព្រមនិងអនុញ្ញាតផ្ទេរលោក **ស្រ៊ិន គឹមស៊** បុគ្គលិកបច្ចេកទេសថ្នាក់មធ្យមអគ្គិសនីនិងក្របខ័ណ្ឌមួយកន្លែងពីអគ្គនាយកដ្ឋាន វិទ្យុជាតិកម្ពុជានៃក្រសួងពត៌មានអោយទៅបំរើការនៅក្រសួង អប់រំយុវជន និង កីឡា ។

ប្រការ ២ : ប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេង ។ របស់សាមីខ្លួន អគ្គនាកយកដ្ឋានវិទ្យុជាតិកម្ពុជាត្រូវសំរួលផ្ទេរបែបបទបញ្ជូនទៅក្រសួងអប់រំយុវជន និង កីឡា ។

ប្រការ ៣ : អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា នាយកដ្ឋានផែនការ គណនេយ្យ ហិរញ្ញវត្ថុ នាយកដ្ឋានបុគ្គលិកនិងរដ្ឋបាល និង សាមីខ្លួន មានភារកិច្ចអនុវត្តតាមប្រកាស ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

ប្រកាស

ភ្នំពេញ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៥

លេខ/២៧០/៩៥/ពម.ប្រក

* * *

អនុញ្ញាតអោយកាសែត «សុជីវធម៌» បោះពុម្ពផ្សាយ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសាន្ត បញ្ញត្តិមាត្រាទី ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- ឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម ០៨៩៥.០៧ ចុះថ្ងៃទី ០១ កញ្ញា ១៩៩៥ ប្រកាសអោយប្រើច្បាប់ស្តីពីរបបសារពត៌មាននៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញលិខិតស្នើសុំរបស់លោក **ជ័យ យ៉ាណូ** ចាងហ្វាងការផ្សាយកាសែត «សុជីវធម៌» ចុះថ្ងៃទី ១៩ តុលា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយកាសែត « **សុជីវធម៌** » បោះពុម្ពផ្សាយដោយមានលោក ជ័យ យ៉ាណូ ជាចាងហ្វាងការផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទនិង សកម្មភាពផ្សព្វផ្សាយត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន ព្រមទាំងស្នើប្រគល់កាសែតចំនួន ០៦ ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤ : លោក **ជ័យ យ៉ារ៉ាឌូ** ចាងហ្វាងការផ្សាយកាសែត « **សុជីវធម៌** » និងនាយកដ្ឋានមណ្ឌលពត៌មាននៃក្រសួងពត៌មានត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

ធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ ២៧១/៩៥ ព.ម.ប្រ.ក

អនុញ្ញាតអោយកាសែត «អរុណរះ »

ដំណើរការបោះពុម្ពផ្សាយ

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិមាត្រា ទី ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់សារពត៌មាន ត្រូវបានសភានៃរដ្ឋកម្ពុជាអនុម័តនាសម័យប្រជុំវិសាមញ្ញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ១
- បានឃើញលិខិតសុំអនុញ្ញាតបើកកាសែតឈ្មោះ « **អរុណរះ** » របស់លោក សុខ សូផាត ជាចាង ហ្វាងការផ្សាយ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយកាសែតឈ្មោះ « អរុណ » ដំណើរការបោះពុម្ពផ្សាយ ដោយមាន លោក **សុខ សុផារត** ជាចាងហ្វាងការផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និង សកម្មភាពផ្សព្វផ្សាយត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និង ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកកាសែត និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន និង ស្មើប្រគល់កាសែតចំនួន ១៥ ច្បាប់ រៀងរាល់លេខចេញផ្សាយមក តំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤ : លោក **សុខ សុផារត** ចាងហ្វាងការផ្សាយកាសែត « អរុណ » និងនាយកដ្ឋានមណ្ឌលពត៌មាន ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ ២៧៣/៩៥ ព.ម.ប្រ.ក

ស្តីពីការលុបឈ្មោះ មន្ត្រី រាជការ

នៅមន្ទីរពត៌មានខេត្តកំពង់ស្ពឺ

* * *

- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច ព្រះ **នរោត្តម សីហនុ** វរ្ម័ន ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៥ អ.ន.ក្រ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

– ពិនិត្យលើសំណើលេខ ៧០ ព.ម.ខ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៩៥ របស់មន្ទីរពត៌មាន ខេត្ត កំពង់ស្ពឺ

សំរេច

ប្រការ ១ : លុបឈ្មោះ **ឃិន ខន** ចេញពីក្របខ័ណ្ឌមន្ទីរពត៌មានខេត្តកំពង់ស្ពឺនៃក្រសួងពត៌មាន មូលហេតុសាមីខ្លួនបោះបង់ចោលការងារ ។

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួន ត្រូវកាត់ផ្តាច់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រការ ៣ : អគ្គនាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ មន្ទីរពត៌មានខេត្តកំពង់ស្ពឺ និង សាមីខ្លួន មានភារៈ អនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

៣ - ទីស្តីការក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ២៣០/៩៥ ក.ធ.ស

«ស្តីពីការអនុញ្ញាតច្បាប់អោយបង្កើតក្រុមជំនុំគ្រិស្តបរិស័ទខ្មែរ នៃ និកាយសេវេនដេយ អាត់វេនទីស្ទ ខេត្តស្វាយរៀង

រដ្ឋលេខាធិការ ក្រសួងធម្មការ និង សាសនា

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាសម្តេចព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង ទី២ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេច ព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋមន្ត្រី និង រដ្ឋ លេខាធិការ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសំណើសុំបង្កើត « ក្រុមជំនុំគ្រិស្តបរិស័ទខ្មែរ នៃនិកាយសេវេនដេយអាត់វេនទីស្ត ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតច្បាប់ជាគោលការណ៍ អោយមានស្នាក់ការ របស់ « ក្រុមជំនុំគ្រិស្តបរិស័ទខ្មែរ នៃ និកាយសេវេនដេយ អាត់វេនទីស្ត » មួយកន្លែង ដែលមានទីតាំងស្ថិតនៅភូមិពាជ័យ ឃុំចម្លង ស្រុកស្វាយជ្រំ ទីរួមខេត្តស្វាយរៀង ខេត្តស្វាយរៀង ។

ប្រការ ២ : ស្នាក់ការនៃ « ក្រុមជំនុំគ្រិស្តបរិស័ទខ្មែរ នៃនិកាយ សេវេនដេយ អាត់វេនទីស្ត » ត្រូវ អនុញ្ញាតអោយផ្សព្វផ្សាយនូវលទ្ធិសាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : ស្នាក់ការនៃ « ក្រុមជំនុំគ្រិស្តបរិស័ទខ្មែរ នៃនិកាយសេវេនដេយ អាត់វេនទីស្ត » ត្រូវគោរពអោយបានម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់សង្គម។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានការពាក់ព័ន្ធត្រូវសហការ អនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសំរេចនេះ មានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

ហៀង ចន្ទ្រាមុន្នី

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ ២៣១/៩៥ កធស-ប្រក

ស្តីពីការទទួលមន្ត្រីរាជការក្នុងក្របខ័ណ្ឌ

ក្រសួងធម្មការ និង សាសនា

* * *

រដ្ឋលេខាធិការ ក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥
- បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយ ប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ដែលរៀបចំ និង ប្រព្រឹត្តិទៅនៃក្រសួងធម្មការ និង សាសនា
- បានឃើញ ប្រកាសលេខ ៥០១ ប្រក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩៥ របស់ក្រសួងមហាផ្ទៃ

សំរេច

ប្រការ ១ : យល់ព្រមទទួលក្របខ័ណ្ឌ ០៣ កន្លែង និង មន្ត្រីរាជការ ៣ នាក់ ក្នុងក្រសួងធម្មការ និង សាសនា ដែលមានឈ្មោះខាងក្រោម :

១ – លោក **នឹម គយ**

២ – លោក **សាន ស្រស់**

៣– លោក **ម៉ិ សុផុន**

ប្រការ ២ : ប្រគល់អស់លោកដែលមានឈ្មោះ ក្នុងប្រការមួយដល់មន្ទីរធម្មការ និង សាសនា ក្រុងព្រះ សីហនុ ជាអ្នកគ្រប់គ្រង និង ចាត់ចែង ។

ប្រការ ៣ : មន្ទីរធម្មការ និង សាសនា មន្ទីរផែនការ មន្ទីរហិរញ្ញវត្ថុ ក្រុងព្រះសីហនុ និង អស់លោក ដែលមានឈ្មោះក្នុងប្រការមួយ ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះរៀងៗ ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

ហឿន វណ្ណារិទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ ២៣២/៩៥ កធស-ប្រក

ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ

* * *

រដ្ឋលេខាធិការ ក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥
- បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយ ប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ដែលរៀបចំ និង ប្រព្រឹត្តិទៅនៃក្រសួងធម្មការ និង សាសនា
- បានឃើញលិខិតលេខ ៨០៦ ស.ជ.ណ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់ក្រសួងមហាផ្ទៃ

សំរេច

ប្រការ ១ : ផ្ទេរក្របខ័ណ្ឌ ០១ កន្លែង និង លោក **កៅ សឿន** នៅក្រសួងធម្មការ និង សាសនា អោយ ទៅបំពេការងារនៅសាលាក្រុងភ្នំពេញ ។

ប្រការ ២ : បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់លោក **កៅ សឿន** ចាប់ផ្តាច់ថ្ងៃទី ០១-១១-១៩៩៥ តទៅ ។

ប្រការ ៣ : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាលហិរញ្ញកិច្ច ការិយាល័យបុគ្គលិក និង លោក **កៅ សឿន** ត្រូវអនុវត្តរៀងៗ ខ្លួន តាមសេចក្តីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

ហៀង វណ្ណារ័ត្ន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ២៣៣/៩៥ កធស.

«ស្តីពីការអនុញ្ញាតច្បាប់ អោយធ្វើសកម្មភាពប្រតិបត្តិគ្រិស្តសាសនា នៃក្រុមជំនុំគ្រិស្តបរិស័ទដំណឹងល្អខ្មែរ» ខេត្តបាត់ដំបង

* * *

រដ្ឋលេខាធិការ ក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង ទី២ របស់រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេច ព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋមន្ត្រី និង រដ្ឋ លេខាធិការ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសំណើសុំអនុញ្ញាតច្បាប់ ធ្វើសកម្មភាពប្រតិបត្តិគ្រិស្តសាសនា នៃក្រុមជំនុំគ្រិស្តបរិស័ទ ដំណឹងល្អខ្មែរ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយធ្វើសកម្មភាពគ្រិស្តសាសនា នៃក្រុមជំនុំគ្រិស្តបរិស័ទដំណឹងល្អ ខ្មែរ «យេរ៉ូសាឡឹម» ដែលមានស្នាក់ការមួយកន្លែងស្ថិតនៅក្រុមទី ៤ ភូមិកម្មករ ឃុំ ស្វាយប៉ោ ទីរួមខេត្តបាត់ដំបង ខេត្តបាត់ដំបង ។

ប្រការ ២ : ស្នាក់ការនៃ « ក្រុមជំនុំគ្រិស្តបរិស័ទដំណឹងល្អខ្មែរ» ត្រូវអនុញ្ញាតអោយផ្សព្វផ្សាយនូវលទ្ធិ សាសនាគ្រិស ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : ស្នាក់ការនៃ «ក្រុមជំនុំគ្រិស្តបរិស័ទដំណឹងល្អខ្មែរ» ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនាសព្វ ជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនា និង សណ្តាប់ធ្នាប់ សង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានការពាក់ព័ន្ធត្រូវសហការអនុវត្តន៍ សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

ហឿន វណ្ណរិត្ថ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ២៣៤/៩៥ ក.ធ.ស.

«ស្តីពីការអនុញ្ញាតច្បាប់ អោយបើកដំណើរការ

ព្រះវិហារគៀនទុចឹលិក នៃសមាគមចឹលិក » ខេត្តបាត់ដំបង

រដ្ឋលេខាធិការ ក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង ទី២ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេច ព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋមន្ត្រី និង រដ្ឋ លេខាធិការ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសំណើសុំច្បាប់អនុញ្ញាតបើកដំណើរការ ព្រះវិហារ ជៀនទូមីលីក នៃសហគមមីលីក ខេត្ត បាត់ដំបង ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតច្បាប់ជាគោលការណ៍អោយ បើកដំណើរការព្រះវិហារជៀនទូមីលីក នៃសមាគម មីលីក ដែលមានទីតាំងមួយកន្លែងស្ថិតនៅក្នុងភូមិ ព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ផ្ទះលេខ២៣-២៤-២៥ ផ្លូវឡាអេ ។

ប្រការ ២ : ព្រះវិហារ ជៀនទូមីលីក ត្រូវអនុញ្ញាតអោយដំណើរ ការផ្សព្វផ្សាយនូវលទ្ធិសាសនាមីលីក ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : ព្រះវិហារ ជៀនទូមីលីក ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង បញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា សន្យាជាដាច់ខាតមិនធ្វើអោយ ប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់សង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានការពាក់ព័ន្ធត្រូវសហការ អនុវត្តន៍ សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

ហៀង វណ្ណរ័ត្ន

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ២៣៥/៩៥ កធស.

«ស្តីពីការអនុញ្ញាតច្បាប់ អោយធ្វើសកម្មភាពប្រតិបត្តិគ្រិស្តសាសនា

នៃក្រុមជំនុំព្រះគ្រិស្ត បេសកកម្មផ្លូវចម្រូត » ខេត្តបាត់ដំបង

* * *

រដ្ឋលេខាធិការ ក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង ទី២ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេច ព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋមន្ត្រី និង រដ្ឋ លេខាធិការ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសំណើសុំអនុញ្ញាតច្បាប់ធ្វើសកម្មភាពប្រតិបត្តិគ្រិស្តសាសនា នៃក្រុមជំនុំព្រះគ្រិស្ត ប្រចាំ ខេត្តបាត់ដំបង ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតច្បាប់ជាគោលការណ៍អោយធ្វើសកម្មភាពពួកជំនុំ នៃព្រះគ្រិស្តបេសកកម្មផ្លូវចម្រូត ដែលមានទីតាំងនៅក្រុមទី ២៥ ភូមិរំគៃវាល ខេត្តបាត់ដំបង ។

ប្រការ ២ : ស្នាក់ការរបស់ពួកជំនុំ នៃព្រះគ្រិស្តបេសកកម្មផ្លូវចម្រូត ត្រូវអនុញ្ញាតអោយធ្វើសកម្មភាពផ្សព្វផ្សាយនូវលទ្ធិសាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : ស្នាក់ការនៃពួកជំនុំព្រះគ្រិស្តបេសកកម្មផ្លូវចម្រូត ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការនិងសាសនា សន្យា ជាដាច់ខាត មិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់សង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានការពាក់ព័ន្ធត្រូវសហការអនុវត្តន៍ សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអានុភាពតតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

ហៀង ចណ្ណារិទ្ធ

* * *

៤ - រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ១០៨៧ សសរ.មស.ក្រខ

ស្តីពី

ការបែងចែកនិស្សិតចំនួន ០១ នាក់ ដែល

ទើបបញ្ចប់ការសិក្សាពីក្រៅប្រទេស

* * *

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

- យោងលិខិតរបស់ទីស្ដីការគណៈរដ្ឋមន្ត្រីលេខ ៣១៩សជណ.ផកចុះថ្ងៃទី ២៨-០២-៩៥
- យោងលិខិតលេខ ៣៦៥ សហវ.ប ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

ប្រការ ១ : ត្រូវបានបែងចែកលោកស្រី **ទេព រដ្ឋា** អ្នកបច្ចេកទេសថ្នាក់ឧត្ដមសេដ្ឋកិច្ច និង សង្គម ដែលទើបបញ្ចប់ការសិក្សាពីប្រទេសរុស្ស៊ី អោយមកបំរើការងារនៅក្នុងក្រ ខ័ណ្ឌក្រសួង ប្រៃសណីយ៍ និង ទូរគមនាគមន៍ ដូចមានក្នុងតារាងខាងក្រោមនេះ ÷

ល.រ	នាមត្រកូល និងនាមខ្លួន	ភេទ	ថ្ងៃខែឆ្នាំ កំណើត	អង្គភាពដើម	មុខជំនាញ បច្ចេកទេស	បៀវត្ស	ប្រភពបណ្ដុះ បណ្ដាល
១	ទេព រដ្ឋា	ស្រី	២០-១០-៦៦	បុគ្គលិកក្រុមហ៊ុន អគ្គិសនីកម្ពុជា	សេដ្ឋកិច្ចផែន ការសង្គម	ខ|.១	ប្រទេសរុស្ស៊ី

ប្រការ ២ : ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានភារកិច្ចទទួលយកលោកស្រី **ទេព រដ្ឋា** ដើម្បី រៀបចំការងារអោយត្រូវតាមមុខជំនាញ និង ផ្ដល់បៀវត្សជូនសាមីជន ចាប់ពី ថ្ងៃដែល គេបានចូលបំរើការងារជាផ្លូវការ ។

ប្រការ ៣ : សេចក្ដីសំរេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ៤ : រាល់សេចក្ដីសំរេចណាដែលផ្ទុយពីខ្លឹមសារខាងលើនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឡោក សុខ

* * *

៥ - ទីស្តីការរដ្ឋមន្ត្រីក្រសួងផែនការ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ ០៧ ផ.ក

ស្តីពីការតែងតាំងគណៈកម្មការប្រឡងជ្រើសរើស

សិស្សជំនាន់ទី VIII ចូលរៀនសាលាមធ្យមសិក្សាផែនការ

រដ្ឋមន្ត្រីក្រសួងផែនការ

* * *

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញលិខិតលេខ ៨៦០ សជណ.អរ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩៥
- បានឃើញសេចក្តីជូនដំណឹងលេខ ២១៧១ អយក.ឧមប ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំយុវជន និង កីឡា ស្តីពីការប្រឡងជ្រើសរើសសិស្សចូលរៀននៅតាមគ្រឹះស្ថាន ឧត្តមសិក្សាបច្ចេកទេស និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញសេចក្តីជូនដំណឹងលេខ ៣៣៥ សណ.ផក ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់ក្រសួងផែនការ ស្តីពីការប្រឡងជ្រើសរើសសិស្សចូលរៀនសាលាមធ្យមសិក្សាផែនការ

សម្រេច

ប្រការ ១ : ចាត់តាំងគណៈកម្មការប្រឡងជ្រើសរើសសិស្សជំនាន់ទី VIII ដែលមានសមាសភាពដូចខាងក្រោម ៖

១-ឯកឧត្តម	**សាន វិចណ្ណៈ**	អនុរដ្ឋលេខាធិការក្រសួងផែនការ	ប្រធាន
២-លោក	**ឆាន សាវន**	ប្រធានមន្ទីរក្រសួងផែនការ	អនុប្រធាន
៣-លោក	**សាន សម**	នាយកសាលាមធ្យមសិក្សាផែនការ	អនុប្រធាន

៤-លោក **សន ស៊ីថន** អនុប្រធានវិទ្យាស្ថានជាតិស្ថិតិ សមាជិក

៥-លោក **ឡូ ទើ** អនុប្រធាននាយកដ្ឋានផែនការទូទៅ សមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ចគ្រប់គ្រង និង ចាត់តាំងគណៈកម្មការ ឬ អនុគណៈកម្មការជា ជំនួយការ ដើម្បីធានាប្រសិទ្ធភាពនៃការប្រឡង ។

ប្រការ ៣ : ឯកឧត្តម អស់លោក ដែលមានរាយនាមនៅក្នុងប្រការ ១ ត្រូវមានភារកិច្ចអនុវត្តសេចក្ដីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ជា ចាន់តូ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៨ ស្ដីពីការចាត់តាំងគណៈកម្មការរៀបចំ និង
ប្រធានវិញ្ញាសាប្រឡងជ្រើសរើសសិស្សជំនាន់ទី VIII ចូលរៀន
សាលាមធ្យមសិក្សាផែនការ

* * *

រដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញសារាចរណែនាំលេខ ០៣ អយក.សរណន. ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ១៩៩៤ របស់ក្រសួងអប់រំយុវជន និង កីឡា ស្ដីពីការរៀបចំចាត់ និង ភារកិច្ចរបស់យន្តការគ្រប់គ្រងការប្រឡង ជ្រើសរើសសិស្សចូលរៀននៅក្នុងគ្រឹះស្ថានមធ្យមសិក្សាបច្ចេកទេស

– បានឃើញសេចក្តីជូនដំណឹងលេខ ៣៣៤ សណ.ផក របស់ក្រសួងផែនការ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការប្រឡងជ្រើសរើសសិស្សចូលរៀននៅសាលាមធ្យមសិក្សាផែនការ សំរាប់ឆ្នាំ សិក្សា ១៩៩៥–១៩៩៦

សំរេច

ប្រការ ១ : ចាត់តាំងគណកម្មការរៀបចំ ប្រធានវិញ្ញាសាប្រឡង ជ្រើសរើសសិស្សជំនាន់ទី VIII ដែលមាសមាសភាពដូចខាងក្រោម ÷

១–ឯកឧត្តម **សាន វិចណ្ណៈ**	អនុរដ្ឋលេខាធិការក្រសួងផែនការ	ប្រធាន
២–លោក **ឆ័ន លាច**	ប្រធានមន្ទីរគ្រួសួងផែនការ	អនុប្រធាន
៣–លោក **សុន ស៊ីផន**	អនុប្រធានវិទ្យាស្ថានជាតិស្ថិតិ	អនុប្រធាន
៤–លោក **ស៊ុំ សន្តិសិទ្ធ**	ប្រធាននាយកដ្ឋានផែនការទូទៅ	សមាជិក
៥–លោក **សាន សម**	នាយកសាលាផែនការ	សមាជិក
៦– លោក **អេង ទេពខ្ជន**	អនុប្រធានការិយាល័យ	សមាជិក
៧–លោក **ទ្រី សុធារិទ្ធ**	អនុប្រធានការិយាល័យ	សមាជិក
៨– លោក **ពោធិ ប៊ុនហ៊ាង**	លេខាឯកឧត្តមរដ្ឋមន្ត្រី	ថតចម្លង

ប្រការ ២ : គណកម្មការនេះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមានក្នុងករណីលេចធ្លាយការសម្ងាត់ នៃប្រធានវិញ្ញាសាគណកម្មការនេះត្រូវស្ថិតនៅក្នុងមណ្ឌលធ្វើវិញ្ញាសា និងមណ្ឌលប្រឡងរហូតដល់ដំណើរ ការប្រព្រឹត្តទៅវិញ្ញាសាបានចាប់ផ្តើមដោយគ្មានបញ្ហា ។

ប្រការ ៣ : ឯកឧត្តម អស់លោក ដែលមានរាយនាមក្នុងប្រការ ១ ត្រូវទទួលភារកិច្ចអនុវត្តតាមប្រកាសនេះចាប់ ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ជា ចាន់តូ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៩ ផក. ស្តីពីការចាត់តាំងគណៈមេប្រយោគសំរាប់

ដំណើរប្រឡងជ្រើសរើសសិស្សជំនាន់ទី VIII ចូលរៀន

សាលាមធ្យមសិក្សាផែនការ

* * *

រដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញសេចក្តីជូនដំណឹងលេខ ៣៣៤ សណផក. ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់ក្រសួងផែនការ ស្តីពីការប្រឡងជ្រើសរើសសិស្សចូលរៀនសាលាមធ្យមសិក្សាផែនការ
- បានឃើញសារាចរណែនាំលេខ ០៣ អយក.សរណន. ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៤ របស់ក្រសួងអប់រំយុវជន និង កីឡា ស្តីពីការរៀបចំចាត់តាំង និង ភារកិច្ចរបស់យន្តការគ្រប់គ្រងការ ប្រឡងជ្រើសរើសសិស្សចូលរៀននៅក្នុងគ្រឹះស្ថានមធ្យមសិក្សាបច្ចេកទេស

សំរេច

ប្រការ ១ : ចាត់តាំងគណៈមេប្រយោគមួយ ដើម្បីជាជំនួយការអោយគណកម្មការប្រឡង ជ្រើសរើសដែលមាន សមាសភាពដូចខាងក្រោម ÷

១– ឯកឧត្តម **សាន វិចណ្ណៈ**	អនុរដ្ឋលេខាធិការ	ប្រធាន
២– លោក **ប៉ាន ឈាវ**	ប្រធានមន្ទីរ	អនុប្រធាន
៣– លោក តំណាងក្រសួងអប់រំ		អនុប្រធាន
៤– លោក **លីវ លីមហ៊ាង**	ប្រធាននាយកដ្ឋានសំណង់	សមាជិក
៥– លោក **អ៊ុក ចាយ**	ប្រធាននាយកដ្ឋានសហប្រតិបត្តិការ	សមាជិក
៦– លោក **សន ស៊ីថន**	អនុប្រធានវិទ្យាស្ថានជាតិស្ថិតិ	សមាជិក

៧- លោក **សាន សម** នាយកសាលាផែនការ សមាជិក

៨- លោក **ឡូ ទើ** អនុប្រធាននាយកដ្ឋានផែនការទូទៅ សមាជិក

៩- លោក **ហុយ សិទ្ធិគុណ** អនុប្រធាននាយកដ្ឋានផលិតកម្ម សមាជិក

១០- លោក **ពាង សាទី** អនុប្រធានការិយាល័យអប់រំ លេខាធិការ

ប្រការ ២ : គណៈមេប្រយោគនេះស្ថិតនៅក្រោមការណែនាំ និង ទទួលខុសត្រូវ ចំពោះគណៈកម្មការប្រឡង ជ្រើសរើសក្នុងការដោះស្រាយរាល់បញ្ហាកើតមានឡើងនៅពេលប្រឡង និង អនុវត្តភារកិច្ចតាមសារាចរ ណែនាំរបស់ក្រសួងអប់រំយុវជន និង កីឡា លេខ ០៣ អយក.សរណារ. ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៤ ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋាន នាយកសាលា ក្រោមឱវាទក្រសួងផែនការ និង អស់លោកដូចមាន រាយនាមក្នុងប្រការ ១ ត្រូវទទួលភារកិច្ចអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ជា. ចាន់តូ

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១០ ផក. ស្តីពីការចាត់តាំងអនុគណៈកម្មការ ត្រួតពិនិត្យសំរាប់ដំណើរការប្រឡងជ្រើសរើសសិស្សជំនាន់ ទី VIII ចូលរៀនសាលាបឋមសិក្សាផែនការ

* * * *

ប្រធានគណៈកម្មការប្រឡងជ្រើសរើស

- បានឃើញសារាចរណែនាំលេខ ០៣ អយក.សរណន. ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ១៩៩៤ របស់ក្រសួងអប់រំយុវជន និងកីឡា ស្តីពីការរៀបចំចាត់តាំងនិងភារកិច្ចរបស់យន្តការគ្រប់គ្រងការប្រឡងជ្រើសរើសសិស្សចូលរៀន នៅក្នុងគ្រឹះស្ថានមធ្យមសិក្សាបច្ចេកទេស

- បានឃើញសេចក្តីជូនដំណឹងលេខ ៣៣៤ សណជក ចុះថ្ងៃទី ០៦ ខែ កញ្ញាឆ្នាំ ១៩៩៥ ស្តីពីការប្រឡងជ្រើសរើសសិស្សចូលរៀនសាលាមធ្យមសិក្សាផែនការ របស់ក្រសួងផែនការ
- បានឃើញប្រកាសលេខ ០៧ ផក ចុះថ្ងៃទី ២៥ ខែ ១០ ឆ្នាំ ១៩៩៥ ស្តីពីការចាត់តាំងគណៈកម្មការប្រឡងជ្រើសរើសសិស្សជំនាន់ទី VIII ចូលរៀនសាលាមធ្យមសិក្សាផែនការ

សំរេច

ប្រការ ១ : ចាត់តាំងអនុគណៈកម្មការត្រួតពិនិត្យពេលប្រឡង និង ត្រួតពិនិត្យលទ្ធផលកំណែវិញ្ញាសា ដើម្បីជាជំនួយការអោយគណកម្មការប្រឡងជ្រើសរើសសិស្សជំនាន់ទី VIII ចូលរៀន សាលាមធ្យមសិក្សាផែនការ ដែលមានសមាសភាពដូចខាងក្រោម ÷

១- លោក **វ៉ែ សៀមគីមសេង**	ប្រធាន
២- លោក **កោះ សំអុល**	អនុប្រធាន
៣- លោក **ខៀវ សារ៉ុន**	សមាជិក
៤- លោក **ម៉ូ សុភាព**	សមាជិក
៥- លោក តំណាងក្រសួងអប់រំ	សមាជិក

ប្រការ ២ : អនុគណកម្មការត្រួតពិនិត្យពេលប្រឡង និង ត្រួតពិនិត្យកំណែវិញ្ញាសាមានភារកិច្ចតាមដានគ្រប់ សកម្មភាពក្នុងដំណើរការរៀបចំប្រធានវិញ្ញាសាក្នុងដំណើរការប្រឡងពិសេសចូលរួមជាមួយគណៈមេ ប្រយោគក្នុងការទុកដាក់ឯកសារប្រឡងអោយបានល្អ និងធានាសុវត្ថិភាពចុះហត្ថលេខាលើក្រដាស បិទទ្វារ ។ល។ និងត្រួតពិនិត្យកំណែវិញ្ញាសាលើសន្លឹកកិច្ចការប្រឡងរបស់បេក្ខជន ។

ប្រការ ៣ : អស់លោកដែលមានរាយនាមក្នុងប្រការ ១ ត្រូវទទួលភារកិច្ចអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សាន វិចណ្ណៈ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩...

ប្រកាស ១១ ផក. ស្តីពីការចាត់តាំងអនុគណកម្មការកណ្តាល និង ក្រុមជំនួយការ សំរាប់ដំណើរការប្រឡងជ្រើសរើស សិស្សជំនាន់ទី VIII ចូលរៀនសាលាមធ្យមសិក្សាផែនការ

* * * * *

ប្រធានគណកម្មការប្រឡងជ្រើសរើស

– យោងប្រកាសលេខ ០៧ ផក. ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការចាត់តាំងគណកម្មការប្រឡងជ្រើសរើសសិស្សជំនាន់ទី VIII ចូលរៀនសាលាមធ្យមសិក្សាផែនការ របស់ក្រសួងផែនការ ។

– តាមសំណូមពរការងារចាំបាច់

សំរេច

ប្រការ ១ : ចាត់តាំងអនុគណកម្មការកណ្តាល និង ក្រុមជំនួយការមួយចំនួនដើម្បីជាជំនួយការអោយគណកម្មការ ប្រឡងជ្រើសរើស ដែលមានសមាសភាពដូចខាងក្រោម

ក– អនុគណកម្មការកណ្តាល

១– លោក ឃិន ឈាន	ប្រធាន
២– លោក ឆេង ទុន្តា លេខានាយកសាលាវិទ្យាល័យទួលទំពូង	អនុប្រធាន
៣– លោក ឃាល់ មួន	អនុប្រធាន
៤– លោក តំណាងក្រសួងអប់រំយុវជន និង កីឡា	សមាជិក
៥– លោក ទេស បញ្ញាធន	សមាជិក

ខ– ក្រុមអប្បមាទ

១– លោក អ៊ុក ចាយ	ប្រធាន
២– លោក អ៊ុន គីមឌី	អនុប្រធាន
៣– លោក គង់ សំអាត	

ច– ក្រុមទទួលវិញ្ញាសាសសេរ និង សរសេរវត្តមាន, អវត្តមានពេលសិស្សប្រឡង

១– លោក អេង ជិនលី ប្រធាន

២– លោក រស់ ស៊ីនួន អនុប្រធាន

៣– លោក លឹម ខុន្ធា សមាជិក

៤– លោក ចាន់ រិទ្ធី សមាជិក

៥– លោក ម៊ិន សាវ៉ាន់ សមាជិក

៦– លោក អ៊ឹម វ៉ាទាញ សមាជិក

៧– លោកស្រី អៀង ពៅ សមាជិក

៨– អ្នកស្រី ហង្ស ផល្លី សមាជិក

ឃ– ក្រុមផ្គត់ផ្គង់, អង្គុលីលេខ រ៉ូណេអូ និង មេក្រូ

១– អ្នកស្រី ស៊ិន ឆារី ប្រធាន

២– លោកស្រី ឃ្លោក សារម៉ិត សមាជិក

៣– លោក ស្វាយ ផារត សមាជិក

៤– លោក គួយ សេដ្ឋា សមាជិក

៥– លោក នាង សុខលី សមាជិក

ង– ក្រុមសន្តិសុខ និង បើកបរ

១– លោក ឈុំប សុផល ប្រធាន

២– លោក ផេន ញឿន

៣– លោក ស៊ុន នន

៤– លោក យិន សំអឿន

៥– លោក ទាសនា

មាត្រា ២ ៖ អនុគណៈកម្មការកណ្តាល និង ក្រុមជំនួយការទាំងអស់មានភារកិច្ច ÷

– អនុគណៈកម្មការកណ្តាល ៖ ទុកដាក់សន្លឹកកិច្ចការប្រឡងរបស់បេក្ខជន សំភារៈផ្សេងៗ និងបែងចែក សំភារៈអោយទៅអនុរក្សអោយបានទាន់ពេលវេលា ។

ប្រការ ៣ : ក្រុមអប្បមាទ : តាមដានសកម្មភាពការងាររបស់អនុគណៈកម្មការនានា និង ក្រុមផ្សេងៗ ដែលចាត់តាំង ឡើងសំរាប់ដំណើរការប្រឡង និង បេក្ខជនក្នុងអំឡុងពេលប្រឡងដើម្បីរាយការជូនប្រធានគណៈ ប្រយោគដោះស្រាយអោយបានទាន់ពេលវេលា ចំពោះឧប្បត្តិហេតុផ្សេងៗ ។

ប្រការ ៤ : អនុគណៈកម្មការកណ្តាល និង ក្រុមជំនួយការទាំងអស់ដូចមានរាយនាមក្នុងប្រការ ១ ត្រូវអនុវត្ត ប្រកាសនេះចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សាន វិចិត្ត

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១២ ផ.ក. ស្តីពីការចាត់តាំងគណៈកម្មការ

កំណែវិញ្ញាសាប្រឡងជ្រើសរើសសិស្សជំនាន់ទី VIII ចូលរៀន

សាលាមធ្យមសិក្សាផែនការ

ប្រធានគណៈកម្មការប្រឡងជ្រើសរើស

- បានឃើញប្រកាសលេខ ០៧ ផ.ក ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការចាត់តាំងគណៈកម្មការប្រឡងជ្រើសរើសសិស្សជំនាន់ទីVIII ចូលរៀនសាលាមធ្យមសិក្សាផែនការ របស់ក្រសួង ផែនការ
- បានឃើញសារាចរណែនាំលេខ ០៣ អយក.សរណន. ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ១៩៩៤ របស់ក្រសួងអប់រំយុវជន និង កីឡា ស្តីពីការរៀបចាត់តាំង និង ភារកិច្ចរបស់យន្តការគ្រប់គ្រងការ ប្រឡងជ្រើសរើសសិស្សចូលរៀននៅក្នុងគ្រឹះស្ថានមធ្យមសិក្សាបច្ចេកទេស

សំរេច

ប្រការ ១ : ចាត់តាំងអនុគណៈកម្មការកំណែវិញ្ញាសាប្រឡងជ្រើសរើសសិស្សជំនាន់ទី VIII ចូលរៀនសាលា មធ្យមសិក្សាផែនការ ដែលមានសមាសភាពដូចខាងក្រោម :

១- លោក **សន ស៊ីថន** ប្រធាន

២- លោក លីន លីមហ៊ាង — អនុប្រធាន

៣- លោក ឡូ វី — សមាជិក

ប្រការ ២ : ចាត់តាំងក្រុមកំណែវិញ្ញាសាប្រឡងជ្រើសរើសសិស្សចូលរៀន អនុសាមញ្ញសិក្សា ផែនការដែលមាន សមាសភាពដូចខាងក្រោម ÷

ក- ក្រុមកំណែវិញ្ញាសាវប្បធម៌ទូទៅ

១- លោក លីន លីមហ៊ាង — ប្រធាន

២- លោក ហ៊ុន ច័ន្ទម៉ុន្នា — សមាជិក

៣- លោក អៀង ឫទ្ធី — សមាជិក

៤- លោក កែម ចំរូល — សមាជិក

៥- លោក យ៉ុន ងីម — សមាជិក

៦- លោក អ៊ុំ ចិនអ៊ី — សមាជិក

ខ- ក្រុមកំណែវិញ្ញាសាភូមិវិទ្យាសេដ្ឋកិច្ច

១- លោក ឡូ វី — ប្រធាន

២- លោក អៀង លីហេង — សមាជិក

៣- លោក ឃួយ សិទ្ធិគុណ — សមាជិក

៤- លោក កែវ សម្បត្តិ — សមាជិក

៥- លោក ចេង រិទ្ធិដារ៉ា — សមាជិក

៦- លោក ម៉ុំ ដារ៉េត — សមាជិក

គ- ក្រុមកំណែវិញ្ញាសាគណិតវិទ្យា

១- លោក សេង ស៊ីខុន — ប្រធាន

២- លោក ពាង សារី — សមាជិក

៣- លោក គួ ជាលី — សមាជិក

៤- លោក គ្រី សុធារិទ្ធ — សមាជិក

៥- លោក ប៉ិច សុវណ្ណទី — សមាជិក

៦- លោក កែត ចិន្ត្រា សមាជិក

ប្រការ ៣ : អនុគណកម្មការដំណើរការកែនេះត្រូវអនុវត្តភារកិច្ច របស់ខ្លួនតាមសារាចរណែនាំលេខ ០៣អយក. សរណន. ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៤ របស់ក្រសួងអប់រំ យុវជន និង កីឡា ។

ប្រការ ៤ : អស់លោកដែលមានឈ្មោះនាមក្នុងប្រការ ១ ត្រូវមានភារកិច្ចអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខា ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សាន វិចណ្ណៈ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៣ ផ.ក. ស្តីពីការចាត់តាំងអនុគណកម្មការ ដំណើរការកែការប្រឡងជ្រើសរើសសិស្សចូលរៀនសាលា មធ្យមសិក្សាផែនការ

* * *

ប្រធានគណៈកម្មការប្រឡងជ្រើសរើស

- បានឃើញសារាចរណែនាំលេខ ០៣ អយក. សរណន. ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ១៩៩៤ របស់ក្រសួងអប់រំយុវជន និង កីឡា ស្តីពីការរៀបចំចាត់តាំង និង ភារកិច្ចរបស់យន្តការគ្រប់គ្រងការ ប្រឡងជ្រើសរើសសិស្សចូលរៀននៅគ្រឹះស្ថានមធ្យមសិក្សាបច្ចេកទេស
- បានឃើញសេចក្តីជូនដំណឹងលេខ ៣៣៤ សណផក. ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការប្រឡងជ្រើសរើសសិស្សជំនាន់ទី VIII ចូលរៀនសាលាមធ្យមសិក្សាផែនការ របស់ក្រសួងផែនការ
- បានឃើញប្រកាសលេខ ០៧ ផក. ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៥ របស់ផែនការ ស្តីពីការចាត់ តាំងកម្មការប្រឡងជ្រើសរើសចូលរៀនសាលាមធ្យមសិក្សាផែនការ ។

សំរេច

ប្រការ ១ ៖ បានតាំងអនុគណកម្មការដំណើរការ ការប្រឡងជ្រើសរើសសិស្សចូលរៀនសាលា
មធ្យមសិក្សាផែនការ ដែលមានសមាសភាពដូចខាងក្រោម ៖

ក- ក្រុមរៀបចំសន្លឹកកិច្ចការ និង បោះត្រា

១- លោក សេង ជិនលី

២- លោក ចេង រិទ្ធិដារា

៣- លោក សៅ ស៊ីនួន

ខ- ក្រុមកាត់ក្បាលសន្លឹកកិច្ចការ

១- លោក ឡាយ សារិទ្ធ

២- លោក យឹម តាំង

៣- លោក ឈឹម ចន្ថា

គ- ក្រុមកាត់លេខសម្ងាត់

១- លោក ប៉ាង ឈាង ប្រធានមន្ទីរក្រសួងផែនការ

២- លោក ហេង សម នាយកសាលា

ឃ- ក្រុមចុះលេខសម្ងាត់

១- អ្នកស្រី ស៊ិន ធារី

២- លោក ចេត បញ្ញារតន

ង- ក្រុមស្រង់ និង បូកពិន្ទុ

១- លោក ប៉ាល់ មួន ប្រធាន

២- លោក គួ ជាលី

៣- លោក តំណាងក្រសួងអប់រំ

ច- ក្រុមដកសន្លឹកកិច្ចការសំរាប់ត្រួតពិនិត្យ

១- លោក ម៉ុន គឹមជ

២- លោក ចាន់ រិទ្ធី

៣- លោក ហ៊ុំ សុផល

គ- ក្រុមត្រួតពិនិត្យ

១- លោក ឆាន់ សាន ប្រធានមន្ទីរក្រសួងផែនការ

២- លោក វ័ន្ត ប៊ុនឡា តំណាងក្រសួងអប់រំ

៣- លោក វ័ន្ត សៀមគីមសេង ប្រធាននាយកដ្ឋានផលិតកម្ម

ឃ- ក្រុមផ្ទៀងផ្ទាត់ចុងក្រោយ

១- លោក គោះ សំអុល អនុប្រធានមន្ទីរ

២- លោក ឆាល់ មួន នាយករងសាលាផែនការ

៣- តំណាងក្រសួងអប់រំ

ប្រការ ២ : អនុគណៈកម្មការដំណើរការនេះ ត្រូវអនុវត្តភារកិច្ចរបស់ខ្លួនតាមសារាចរណែនាំលេខ ០៣ អយក. សរណន. ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៤ របស់ក្រសួងអប់រំយុវជន និង កីឡា ។

ប្រការ ៣ : អស់លោកដែលមានរាយនាមក្នុងប្រការ ១ ត្រូវមានភារកិច្ចអនុវត្តន៍តាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សាន វិវណ្ណៈ

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស

លេខ ១៤ ផក ស្តីពីការចាត់តាំងអនុគណៈកម្មការ

អនុក្រុមដំណើរការប្រឡងជ្រើសរើសសិស្សជំនាន់ទី VIII

ចូលរៀនសាលាមធ្យមសិក្សាផែនការ

ប្រធានគណៈកម្មការប្រឡងជ្រើសរើស

- បានឃើញប្រកាសលេខ ០៧ ផក ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការចាត់តាំងគណៈកម្មការប្រឡងជ្រើសរើសសិស្សជំនាន់ទី VIII ចូលរៀនសាលាមធ្យមសិក្សាផែនការរបស់ក្រសួងផែនការ

– តាមសំណូមពរការងារចាំបាច់

សម្រេច

ប្រការ១ : បាត់តាំងអនុគណៈកម្មការមួយ ដើម្បីជាជំនួយការអោយគណៈកម្មការប្រឡងជ្រើសរើសសិស្សជំនាន់ទី VIII ចូលរៀនសាលាមធ្យមសិក្សាផែនការដែលមានសមាសភាពដូចខាងក្រោម ៖

ក/ អនុគណៈកម្មការអនុរក្ស :

១–លោក ឈឹម ឈឹមហ៊ាន	ប្រធាន
២–លោក ខៀវ សារី	អនុប្រធាន
៣–លោក ហ៊ុន ចំនួនម៉ុន្ថា	សមាជិក
៤–លោក ចន្ទ សាម៉ុន	សមាជិក
៥–លោក គួ ចាន់លី	សមាជិក
៦–លោក យឹម តាំង	សមាជិក

ខ/ ក្រុមពិនិត្យអនុរក្ស :

១–លោក ខៀវ សារី	ប្រធាន
២–លោក ហ៊ុន ចំនួនម៉ុន្ថា	អនុប្រធាន
៣–លោក ចន្ទ សាម៉ុន	សមាជិក
៤–លោក យឹម តាំង	សមាជិក
៥–លោក គួ ចាន់លី	សមាជិក
៦–លោក ឡាយ សារិទ្ធ	សមាជិក
៧–លោក ហួយ សិទ្ធិគុណ	សមាជិក

គ/ បាត់តាំងអនុរក្ស :

១–លោក គឹម ចិត្រល	១៩–លោក ប៊ូច សុវណ្ណឌី
២–លោក ចេង រិទ្ធិដារា	២០–លោក ឌឹម ឆេរិទ្ធ
៣–លោក ហ៊ុន សុផល	២១–លោក នួន ដា

៤-កញ្ញា អេង គន្ធីរ៉ា

៥-លោក យឹម ឌឹម

៦-លោក ម៉ឹម ម៉ារ៉ាឌី

៧-លោក ម៉េត រូបរក្សា

៨-លោក អ៊ូ ឆោម

៩-លោក ឃ្លី ផាន់ណារ៉ា

១០-លោក ប៊ុន តេច

១១-លោក ឌឹង ឡេង

១២-លោក ម៉ូ ម៉ៅ

១៣-លោក យ៉េម សុផារម្យ

១៤-លោក នួច មិនា

១៥-លោក ស៊ិច កែត

១៦-លោក ម៉ូ ដារីណា

១៧-លោក ហាន ថាវរៈ

១៨-លោក [illegible] ចាន់សុខា

៣៧-លោកស្រី ម៉ៅ ស៊ីផុន

៣៨-លោក ហ៊ូ តិច

៣៩-លោក ជា សុវណ្ណ

៤០-លោក សែន ទាសនា

៤១-លោក យ៉ាន់ ជំនិត

៤២-លោក ម៉ឹម [illegible]

៤៣-លោក ខួន លីវឌ្យ

៤៤-លោក ឆឹច ឈាងអាន

៤៥-លោក សួន សុគ្គី

២២-លោក ស៊ុន សេដ្ឋា

២៣-លោក ឆយ ឃឿន

២៤-លោក ម៉ឹម បូរ៉ាត

២៥-លោក អ៊ុត អ៊ិចអ៊ី

២៦-លោក លី ទុឡា

២៧-លោក គីម ចន្ទារិទ្ធ

២៨-លោក រស់ ឆាត

២៩-លោក ជួន ណារិន

៣០-លោក ស៊ូ សាត

៣១-លោក ផន ណារ៉ូ

៣២-លោក កែវ ពៅ

៣៣-លោក ហ៊ុន ពិសាល

៣៤-លោក សួន ជួន

៣៥-លោក ចិន សៅ

៣៦-លោកស្រី សុត ស៊ីថន

៥៧-លោក ចាន់ និប៊ុល

៥៨-លោក គង ស៊ីផាន់ណារ៉ា

៥៩-លោក ស៊ុំ វណ្ណសាន

៦០-លោក សុខ បូរិទ្ធ

៦១-កញ្ញា កុង សៃរិន

៦២-លោក ហ៊ាង ការុណ

៦៣-លោក អឿ សុផល

៦៤-លោក ហង់ ចាន់ថុល

៦៥-លោក ស៊ឹម សុគន្ធ

៤៦-លោក អៀង លីហេង	៦៦-លោក ឌុយ ណារ៉េត
៤៧-លោក ខំ ហេង	៦៧-កញ្ញា ម្លូ ម៉ូឡាយ
៤៨-លោក សោម ផុន	៦៨-កញ្ញា ហែម ម៉ូនីកា
៤៩-លោក ឡាយ ផារិន	៦៩-លោក ស៊ុម សេត
៥០-លោក កែវ អ៊ូលី	៧០-លោក តឹង តេជោរតនច័ន្ទ
៥១-លោក ស៊ឹម ឡាយ	៧១-លោក ទ្រី ម៉េងស៊ាង
៥២-លោក ស៊ឹម ទាយ	៧២-លោក ប៊ុត សេង
៥៣-លោក ឡុង សារ៉េត	៧៣-លោក លី គី
៥៤-លោក អៀង រិទ្ធី	៧៤-លោក ប៉ាន់ សុខុម
៥៥-លោក ឆែ ម្	៧៥-លោក ខូន និស្ស័យកុសល
៥៦-លោក ឈាង ទ៊ាន់ថា	

ប្រការ២ អនុគណៈកម្មការអនុរក្សនេះ ស្ថិតនៅក្រោមការណែនាំរបស់គណៈកម្មការប្រឡងប្រណាំងជ្រើសរើស និងទទួលខុសត្រូវចំពោះមុខ គណៈកម្មការប្រឡងជ្រើសរើស ក្នុងការដោះស្រាយរាល់បញ្ហាកើតមានឡើងនៅពេលប្រឡង ។

ប្រការ៣ អនុគណៈកម្មការអនុរក្សត្រូវចាប់ផ្តើមការងាររបស់ខ្លួន ចាប់ពីថ្ងៃទី ២៧ ខែ តុលា ឆ្នាំ១៩៩៥ ពីម៉ោង ៦:០០ ព្រឹក ដល់ថ្ងៃទី ២៨ ខែតុលា ឆ្នាំ ១៩៩៥ ។

ប្រការ៤ អស់លោកប្រធាន អនុប្រធាន នាយកដ្ឋាន ក្រោមឱវាទក្រសួងផែនការ និងអស់លោកដូចមានរាយនាមក្នុងប្រការ១ ត្រូវទទួលភារកិច្ចអនុវត្តតាមប្រកាសនេះ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

សាន វិចណ្ណៈ

* * *

៦- ទីស្តីការ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ ; ៧៨៩ ឧក.ប្រក

* * *

ប្រការ១ : អនុញ្ញាតអោយ លោក **ហេង ម៉ិុយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣០៤១៨០ ក.ព ចុះថ្ងៃទី ០២-៤-៩១ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៥៣២ ផ្លូវជាតិ លេខ៥ ក្រុមទី៩ ភូមិ ស្ពានខ្ពស់ សង្កាត់ គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវរាជធានីភ្នំពេញ បន្តដំណើរការផលិតកម្ម និងពង្រីកបន្ថែមនូវមុខផលិតផលស្រាកែច្នៃនៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ២ : លោក **ហេង ម៉ិុយ** ត្រូវបានអនុញ្ញាតអោយផលិត នូវស្រាកែច្នៃសញ្ញា « រូបគស្ឋាន » និង « ផ្លែគៀមបួយ » បន្ថែមលើមុខផលិតផលចាស់ចំនួន ៣មុខ ទៀត គឺស្រាកែច្នៃសញ្ញា «គីង្គក់ » , « ស្នែងទន់ » និង « ខ្លាឃ្មុំ » ស្របតាមគំរូសញ្ញាសំគាល់ដែលបាន តំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផល គ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ៧៩០ ឧក.ប្រក

ប្រការ ១ : អនុញ្ញាតអោយ លោក **ឈុន គេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២២៧០០៦ ក.ណ ចុះថ្ងៃទី ៣០ - ០១ - ៨៩ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៤២៨ ផ្លូវជាតិ លេខ៥ ក្រុមទី៧ ភូមិ ស្ពានខ្ពស់ សង្កាត់ គីឡូម៉ែត្រលេខ៦

ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ បន្តដំណើរការផលិតកម្ម និងពង្រីកបន្ថែមនូវមុខផលិតផល ស្រាកែច្នៃ នៅក្នុងទីតាំង ដូច អាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ឈុន អេង** ត្រូវបានអនុញ្ញាតអោយផលិតនូវស្រាកែច្នៃសញ្ញា «ស្រាវិស្គីណាំបឺរ៉ន (I) » បន្ថែមលើមុខផលិតផលចាស់ចំនួន ១មុខទៀត គឺ ស្រាកែច្នៃសញ្ញា «មេដែមាស»ស្របតាមគំរូសញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតពេលកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផល គ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ៧៩១ ឧក. ប្រក

ប្រការ ១ : អនុញ្ញាតអោយ លោក **ជឹង ឆីអៀង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៣១០៩០ ភ.ព ចុះថ្ងៃទី ០៤ - ៦ - ៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥២២ ផ្លូវជាតិ លេខ៥ ក្រុមទី៩ ភូមិ ស្ពានខ្ពស់ សង្កាត់ គីឡូម៉ែត្រលេខ៦ ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ បន្តដំណើរការផលិតកម្ម និងពង្រីកបន្ថែម នូវមុខផលិតផលស្រាកែច្នៃ នៅក្នុង ទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ជឹង ឆីអៀង** ត្រូវបានអនុញ្ញាតអោយផលិត នូវស្រាកែច្នៃសញ្ញា «ទំពាំងបាយជូ » និង «សេះសារិស្គី » បន្ថែមលើមុខផលិតផលចាស់ចំនួន ២មុខទៀត គឺស្រាកែច្នៃសញ្ញា «ស្ពានមាស » និង « រាញី » ស្របតាមគំរូសញ្ញា សំគាល់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត

ល្មើសច្បាប់ ផលិតផល គ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្ក អោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងដកហូតវិញដោយគ្មានសំណង ឡើយ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

អ៊ិត ប្រាំង

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៨

ប្រកាស លេខ : ៧៩៣ ឧស.ប្រក

ប្រការ ១ : អនុញ្ញាតអោយ លោក ពេជ សុវណ្ណ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៥៦៩៧៨ ក.ព ចុះថ្ងៃទី ០១-១០-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២៩២ អឺ០ ផ្លូវលេខ ២១៧ សង្កាត់ អូរឬស្សីទី២ ខណ្ឌ៧មករា រាជធានីភ្នំពេញ បន្តដំណើរការផលិតកម្ម ឧស្សាហកម្មតូចផលិតថ្នាំលាប នៅក្នុងទីតាំងអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក ពេជ សុវណ្ណ ត្រូវបន្តដំណើរការផលិតកម្ម - អាជីវកម្មនូវមុខផលិតផល ថ្នាំលាបសញ្ញា «វិមានជ័យជំនះ » ស្របតាមគំរូផ្លាកសញ្ញាសំគាល់ដែលបានតំកល់ទុក នៅក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណី ប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយ មានការប៉ះពាល់ដល់បរិស្ថានប្រកាសនេះនឹងដកហូតវិញ ដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរ

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ៧៩៤ ឧក. ប្រក

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ឡេង សុខឃាង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជាកាន់អត្តសញ្ញាណប័ណ្ណ លេខ ២៨៤៩៩២ ក.ព ចុះថ្ងៃទី ២៧ - ១១ - ៩០ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២០ ផ្លូវលេខ ៣០០ សង្កាត់ អូឡាំពិក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការផលិតកម្ម ទឹកកកដើម នៅក្នុងទីតាំង ក្រុមទី៣២ សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផល គ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ៧៩៥ ឧក. ប្រក

ប្រការ ១ : អនុញ្ញាតអោយ លោក **ទ៉ែន ទាសនា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ៣៤៤១២៤ ក.ព ចុះថ្ងៃទី ១៣ - ១០ - ៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ១៦៨៤ ក្រុមទី១ ភូមិផ្សារតូច សង្កាត់ ទួលសង្កែ ខ័ណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ បើកដំណើរការ រោងម៉ាស៊ីនផលិតថាមពលអគ្គិសនី ដោយប្រើម៉ាស៊ីន ចំនួន ២គ្រឿង ដែលមានកំលាំងសរុប ២៤០KVA នៅក្នុងទីតាំងផ្ទះលេខ ៦៨៣ ផ្លូវលេខ ៦A ក្រុមទី៩ ភូមិគៀនឃ្លាំង ១ សង្កាត់ ព្រែកលាប ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **ទ៉ែន ទាសនា** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបាន កំណត់ក្នុងប្លង់ ដោយធានាអោយបាននូវសុវត្ថិភាពការងារ និងភាពសុចរិតក្នុងអាជីវកម្មរបស់ខ្លួន ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត

ល្មើសច្បាប់ ឬ, បង្កអោយ មានការប៉ះពាល់ដល់បរិស្ថានប្រកាសនេះនឹងដកហូតវិញ ដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពៅ សុធីរៈ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ៧៩៦ ឧក. ប្រក

ប្រការ ១ : អនុញ្ញាតអោយ លោក **ឈឹម ហុន** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១២៦៤១៦ ភ.ព. ចុះថ្ងៃទី ៣១-៥-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ៥៣០ បេ ផ្លូវជាតិលេខ៥ ក្រុមទី៩ ភូមិស្ពានខ្ពស់ សង្កាត់ឫស្សីកែវ ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ បន្តដំណើរការផលិតកម្ម និងពង្រីកបន្ថែមមុខផលិតផល ស្រាកែច្នៃ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ឈឹម ហុន** ត្រូវបានអនុញ្ញាតអោយផលិតស្រាកែច្នៃ សញ្ញា «រូប ស្វាខ្មៅ» និង «ផ្លែឈើចំរុះ » បន្ថែមលើមុខផលិតផលចាស់ ចំនួនបីមុខទៀត គឺស្រាកែច្នៃ សញ្ញា « សាច់ជុំ »,« យិនសិនរូបមនុស្ស » និង « ឥន្ទ្រី » ស្របតាមគំរូសញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ពេលកំណត់ផុតនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផល គ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថានប្រកាសនេះនឹងដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

អ៊ិត ប្រាំង

* * *

៧ - ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៧៣ ប្រក.វវស.បុ

ស្តីពីការតែងតាំងមន្ត្រីរាជការ មន្ទីរវប្បធម៌

និងវិចិត្រសិល្បៈ ខេត្ត ព្រះវិហារ

* * *

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ - ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើតំលើងឋានៈមន្ត្រីរាជការ លេខ ១២១ - ៩៥ វវស ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ១៩៩៥ របស់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តព្រះវិហារ
- យោងតាមចំណារយល់ព្រមពីឯកឧត្តមរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : ត្រូវបានតែងតាំងមន្ត្រី រាជការចំនួន ០៣ « បី » នាក់ ដូចមានរាយនាមខាងក្រោម នេះ មានឋានៈជាប្រធានការិយាល័យ និងអនុប្រធានការិយាល័យរបស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តព្រះវិហារ ក្រោមនិភាគក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ÷

១- លោក **ឈឹម សុវណ្ណផល្លា** អនុប្រធានការិយាល័យរដ្ឋបាលត្រូវបានតែងតាំងជាប្រធានការិយាល័យរដ្ឋបាល-បុគ្គលិក

២– លោក នៅ សុគុណា ប្រធានគណនេយ្យ ត្រូវបានបានតែងតាំងជាអនុប្រធានការិយាល័យទទួលបន្ទុកផែនការ គណនេយ្យ និង ហិរញ្ញវត្ថុ

៣– លោក ឈុម ខិត អនុប្រធានការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈ ស្រុកជ័យសែន ត្រូវបានតែងតាំងជាប្រធានការិយាល័យវប្បធម៌ និង វិចិត្រសិល្បៈ ស្រុកជ័យសែន ។

ប្រការ ៖ ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តព្រះវិហារ ព្រមទាំងសាមីខ្លួនមានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

នុត ណារ៉ាង

* * *

បោះពុម្ពនៅរោងពុម្ពធីស្ថិការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៩៥២ រៀល